BMI0195

# សម្ភាសន៍ជាមួយឈ្មោះ ធន់ ធី ភេទប្រុស អាយុ៩១ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ប្រធានកងកុមារនៅត្រពាំងថ្ម

## រស់នៅភូមិប៉ោយតាប៉ែន ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ចាន់ ប្រុញ

០១:១៦:០៦

៣២ទំព័រ

ប្រុញ : ពួកខ្ញុំម៉ោពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា គ្រាន់តែយើងចងក្រងឯកសារពីសម័យខ្មែរក្រហមហ្នឹងលោកពូ ព្រោះខ្ញុំចង់ដឹងថា តើប្រជាជននយើងធ្វើការអីខ្លះ នៅត្រពាំងថ្មហ្នឹង ហើយគេឲ្យយើងធ្វើការយ៉ាងម៉េចខ្លះ ដើម្បីចងក្រងជាឯកសារទុកឲ្យកូនចៅជំនាន់ក្រោយមើល ។ បើពូធ្លាប់ឆ្លងកាត់អញ្ចឹង បើពូអត់និយាយប្រាប់គាត់អត់ដឹងទេ ក្មេងជំនាន់ក្រោយដូចពួកខ្ញុំអីចឹង?

ធី : អ្ហូ! ខ្ញុំវេទនាណាស់សម័យហ្នឹង ខ្ញុំហើមដៃ ហើមជើង វែកដីបណ្ដើរយំបណ្ដើរអត់ហ៊ានឈប់ទេ ព្រោះខ្លាចគេយកទៅវ៉ៃចោល ។ ខ្ញុំខ្វាក់មាន់ដើរបុកគល់ឈើៗ ចុះល្ងិតនោះ អាអ្នកដឹកដៃយើងដើរវាប្រលែងយើងចោល គេប្រលែងចោល ខ្ញុំស្រវែស្រវ៉ាចូលទៅក្នុងប្រទាក់ដេកនៅនោះ ដេកដល់ប្រធានកងបាត់ស្រែកហៅរកខ្ញុំ ។ ខ្ញុំនៅនេះ អាអ្នកអន្ទុយយំៗទៅ អាអ្នកឆ្លើយៗទៅ ហើយបានគេមកយក ។ តាវ៉ាល់ ថាអញបាត់គ្នា ២-៣នាក់ គាត់ដេញឲ្យប្រធានវរៈទៅរក ។

ប៊ុនថន : ពូស្គាល់គាត់ដែរ តាវ៉ាល់?

ធី : មិនស្គាល់ម៉េច ពេលប្រជុំម្ដងៗ សាហាវអស់ទាស់តា ។

ប៊ុនថន : ម៉េចគាត់កាចអីម៉េច?

ធី : កាច គាត់រៀនថ្នាក់ខ្ពស់ ថ្នាក់ទី៥ ទី៦ ។

ប៊ុនថន : គាត់អ្នកចេះដឹងដែរ?

ធី : បាទ! កាលសម័យសង្គ្រាមនោះ គាត់រត់ចូលព្រៃ តាហ៊ីង ។ តាហ៊ីងហ្នឹងឪគាត់សក្ដិ៥ តាហ៊ីងថ្នាក់តំបន់ហ្នឹងឪគាត់សក្ដិ៥ ។

ប៊ុនថន : ស្គាល់តាហ៊ីងដែរ?

ធី :		អីមិនស្គាល់ម៉េច តាហ៊ីង គាត់ទៅប្រជុំនៅអាងត្រពាំងថ្ម ដើរកាន់តែកន្សែងស្ងួតគ្រប់បេះ ដើរបក់បេះ ។

ប៊ុនថន :	ចុះតា ញឹម អីស្គាល់ទេ?

ធី :		ស្គាល់ តាញឹម រាងខ្មៅ មាឌមាំ ។

ប៊ុនថន :	តាញឹមដន្ទង សោ ភឹម? រស់ ញឹម?

ធី :		មិនស្គាល់ទេ! ស្គាល់តែតាញឹម ប្រធានភូមិភាគ តាជាល ហ្នឹងឯង ពេលដែលយើងលើកទំនប់រួច គាត់ទៅត្រួតពិនិត្យមើល ។

ប៊ុនថន :	តាជាល ត្រូវកូនតាញឹម នោះ?

ធី :		បាទ! ងាប់អស់ហើយសម័យហ្នឹង វៃបន្តគ្នា ។

ប៊ុនថន :	បាទ! ចុះយាយ ចែម អីពូស្គាល់ទេ?

ធី :		យាយ ចែម មិនសូវឃើញច្បាស់ទេ ។ និរតី គាត់នៅតែភ្នំលាប ភ្នំហ្នឹងហើយចល័តតំបន់ បើថាពួកក្រុមចល័តតំបន់ហ្នឹង បើឆ្នាំ៧៦-៧៧អីខ្ញុំស្គាល់ច្បាស់ ៧៨និរតីម៉ោហើយ ។ ៧៨និរតីម៉ោពួកខ្ញុំនៅចល័តត្រពាំងថ្មងាប់ចង់អស់ ។

ប៊ុនថន :	អ្ហូ!ម៉េចអញ្ចឹង?

ធី :		គេយលវៃចោល តាស្រេះ តាស្រេន តាយ៉ាវ គេយកទៅវៃចោលត្រពាំងថ្មទាំងអស់ ។ ឲ្យតែគេថា យកទៅរៀនស្វាត់ជ្រៀបៗ ។

ប៊ុនថន :	ចុះត្រពាំងថ្មគេលើកចាប់ពីឆ្នាំណាវិញពូ?

ធី :		ត្រពាំងថ្មគេចាប់ផ្ដើមលើកចាប់ពីឆ្នាំ៧៧ ។

ប៊ុនថន :	៧៧ បានចាប់ផ្ដើមធ្វើ ដំបូងពូ?

ធី :		បាទ! ៧៧ ខែពីរចុះ យប់ការងារខ្លាំង ប្រូតៗឡើងទៅទាំងយប់ ដេកព្រៃមាន់នេះ ភ្លឺព្រាងៗប្រហែលម៉ោងបួន ក្រោកដើរស្ទាបៗ ដើរទំរាំដល់ម៉ោង៨-៩ ។ សុទ្ធតែដើររែកបង្គី រែកចប ។

ប៊ុនថន :	មុនដំបូង ពេលពូទៅធ្វើមុនដំបូងគេហ្នឹងពូ?

ធី :		ដំបូងទំនប់កំពោរនេះ ។

ប៊ុនថន :	យាយត្រពាំងថ្ម?

ធី :		ត្រពាំងថ្មមុនដំបូង ចាំមើលខ្ញុំនិយាយ ចេញចល័ត លើកទំនប់កំពោរ លើកទំនប់កំពោរនេះរួចបាន លើកទំនប់ស្រះៗរួចបានទៅលើកស្ពាច់ៗរួច បានទៅធ្វើចំការកប្បាស

កងវ៉ាទៅកាប់ព្រៃដេកនៅហាលព្រៃ ហាលភ្លៀង ដេកហាលភ្លៀងទទួលភួយ ទទួលមុងទៅ ។ ដេកភ្លៀងរលឹមសឹចៗខែបិណ្ឌនោះ តស៊ូឡើងៗ អាអ្នកស៊ូមិនបានរត់ទៅផ្ទះទៅ អ្នកនៅបេះតែនៅទៅ មិនដឹងថារត់ទៅណា រត់ទៅខ្លាចគេតាមទាន់ ខ្លាចគេយកទៅវ៉ៃចោល ។ នឹកឃើញថានៅងាប់នេះក៏ងាប់ទៅ ទៅដេកពេទ្យអឺចឹងទៅមួយថ្ងៃដេកមួយយប់ពីរយប់ចេញ ចុះខ្មោចងាប់រាល់ថ្ងៃ សែងកប់រាល់ថ្ងៃយុវជន ប៉ុន្មានយុវជនងាប់ច្រើនណាស់ មួយថ្ងៃពីរ មួយថ្ងៃបីអ៊ូ!ងាប់ច្រើនណាស់ ។ ចុះកុមារវាតែបាយប៉ុននេះវាស៊ីទៅវាធូន់ពោះគ្រាន់ហើយ បើយុវជនតែ២ចានហ្នឹង ស៊ីមិនឆ្អែតគ្នាស្គម គ្រុនក្តៅរាគមួលៗក៏ទៅហ្នង ។

ប៉ុនថន : បាទ! អឺចឹងខ្ញុំចង់សួរពូ កាលពីដំបូង កាលពីកុមារហើយរហូតមកដល់សម័យ៣ឆ្នាំ ហើយក្រោយមកទៀត អឺចឹងពូអាចរៀបរាប់ដែលពូចាំ បានទេលោកពូ?

ធី : បាន ។

ប៉ុនថន : អឺចឹងកុំឲ្យខាតពេលខ្ញុំសួរឈ្មោះលោកពូហ្នង លោកពូឈ្មោះអីដែរ?

ធី : ឈ្មោះ ធន់ ធី ។

ប៉ុនថន : សព្វថ្ងៃអាយុប៉ុន្មានហើយលោកពូ?

ធី : អាយុ៥១ហើយ ព្រោះកើតនៅឆ្នាំ១៩៦០ ។ បើដល់៧៥ ខ្ញុំអាយុ១៥ឆ្នាំ ៧១ខ្ញុំអាយុ១៦ ៧៧អាយុ១៧ ៧៨អាយុ១៨ ។ សម័យយួនចូលម៉ោ៧៩ ខ្ញុំអាយុ១៩ហើយ ។

ប៉ុនថន : បាទ! លោកពូមានស្រុកកំណើតនៅភូមិ ឃុំអីដែរ?

ធី : នៅភូមិប៉ោយតាប៉ែន ឃុំព្រះនេត្រព្រះ ។

ប៉ុនថន : ស្រុកកំណើតនៅហ្នឹងដែរ?

ធី : បាទ! ប៉ុនសម័យប៉ុល ពត គេដូរឲ្យទៅនៅទំនប់ប៉ោយសំរោងនោះ គេដូរភូមិគ្នា អត់ឲ្យនៅភូមិដដែលទេ ខ្លាចយើងមានកម្មសិទ្ធិៗផ្ទះ កម្មសិទ្ធិដើមដូងដីធីអីគ្មានកម្មសិទ្ធិទេ សុទ្ធតែរបស់អង្គការទាំងអស់ម៉យនោះ ។

ប៉ុនថន : ភូមិប៉ោយតាប៉ែន ហ្នឹងភូមិពីដើមម៉ោហ្នងពូ?

ធី : បាទ!ភូមិកំណើតពីដើម ពីយាយតាម៉ោពីដើម ។

ប៉ុនថន : ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ធី : បងប្អូនខ្ញុំបើគិតទៅវា៥ ប៉ុនងាប់អស់កំប៉េះហ្នឹង ។ ងាប់អស់បង ហឿន មួយហ្នឹងសម័យប៉ុល ពតហ្នឹងគេយកទៅវ៉ៃចោល ។

ប៊ុនថន : គាត់ខុសអីបានគេវៃចោលពូ?

ធី : យើងរៀនថ្នាក់ខ្ពស់ ពុកខ្ញុំធ្វើទាហាន សម័យលន់ នល់ ពុកខ្ញុំក៏គេយកទៅវៃចោល ។

ប៊ុនថន : វៃនៅណាវិញពូ?

ធី : មិនដឹងថាគេយកទៅវៃនៅណា គេមកហៅពីបន្ទាយយកទៅ ។ ពុកខ្ញុំទាហានសម័យលន់ នល់ បងខ្ញុំរៀនឌីប្លូមពីដើម រៀននៅស្វាយ ថ្នាក់ទីពពីសង្គមចាស់ សាលាសម្តេចឪ ដល់គេស្រាវជ្រាវប្រវត្តិទៅ គាត់អ្នកចេះ មុនដំបូងគេយកពីនោះម៉ោ ដាក់រទេះសេះម៉ោគរបីនេះ គោករំចេកនេះ ។

ប៊ុនថន : ដើមគរពដើមនេះ?

ធី : បាទ!គេយកប្រវត្តិម៉ោ គេអត់ដឹងថាឪពុកធ្វើទាហានទេ ប៉ុន្តែគ្នាឯងនេះ ។

ប៊ុនថន : អ្ហូ!ពីណាវិញលោកពូ?

ធី : ពូថាគេរើសម៉ោឲ្យធ្វើនៅកន្លែងសាលា គ្រាន់ធ្វើបញ្ជីឡើងតាមភូមិ តាមស្រុក ។ រត់ការណ៍ រត់សំបុត្រតាមស្រុក ។ ដល់នេះក៏គាត់ថា យកៗខ្ញុំមិនចេះអក្សរអីចឹង អ៉ើ!ហានគេប្រាប់ខ្ញុំ ។ ខ្ញុំមិនសូវចេះអក្សរទេ ហាននោះគេរៀនបានថ្នាក់ខ្ពស់ អក្សរគាត់ស្អាត អក្សរគាត់ស្អាតមែន បារាំង អង់គ្លេសគាត់ចេះ ។

ប៊ុនថន : កាលហ្នឹងខាងណាមកយកវិញ?

ធី : ខាងនិរតី ខាងតំបន់៥ ហើយគេសុទ្ធតែអ្នកចេះ ណេ៎!បងឈ្មើមៗ ហ្នឹងរៀនជាមួយគ្នា ហើយនៅធ្វើការជាមួយពួកម៉ាក គេឲ្យជ្រើសរើស គេមានយោបាយគេស្អាត ។ ដល់នេះគេថា មានស្គាល់អ្នកណាដែលចេះអក្សរដូចគ្នាទេ ហើយគាត់ប្រាប់អ្នកធ្លាប់រៀនថ្នាក់ជុំគ្នា ។

ប៊ុនថន : ហៅទៅបាត់រហូតហង?

ធី : បាទ! ដល់ខ្ញុំម៉ោនេះបានមួយខែ ពីរខែនោះ បានវាំនាំទៅវែក យកមកកកុំឲ្យវាដឹងខ្លួនយើង យកមកចូលឲ្យយើងរត់ទៅនេះទៅនោះ(ស្តាប់មិនបាន) ។

ប៊ុនថន : ប៉ុន្តែក្រោយម៉ោមានបានពូដំណឹងគាត់?

ធី : អត់!គាត់ថាទៅរៀន ទៅរៀនយកឡានទៅដឹក(ស្តាប់មិនបានមេឃភ្លៀង) អឺទៅរៀនបាត់ជ្រៀមគ្មានដំណឹង គាត់ទៅនៅធ្វើការនៅរហាល ធ្វើការកាប់គាស់ជាមួយម៉ែៗ នៅបានប្រហែលម៉ាអាទិត្យ គេហៅយកទៅដាក់ឡានយកទៅថា ទៅរៀនរៀបចំឥវ៉ាន់ ខោអាវមិនសង្ស័យថារស់ទេ ។

ប៊ុនថន : អាហ្នឹងបង ចុះបន្ទាប់មក?

ធី : បន្ទាប់មកពុកខ្ញុំៗ ដឹងតែគេបោសសំអាតអាពួក អា បេ សេ ដេ (ABCD) សម័យដែលយើងវ៉ៃម៉ោហ្នឹង គេស្រាវជ្រាវទាហានសម័យ លន់ នល់ (សេ អ៊ី អា) ស្រាវជ្រាវហៅយកទៅ។

ប៊ុនថន : ហៅពីណាយកទៅ?

ធី : ពីភូមិប៉ៅយសំរោងហ្នឹង តែគេហៅទៅដឹងតែស្រេចហើយ។ ឲ្យគាត់រត់គាត់មិនរត់ គាត់ថាមិនដឹងរត់ទៅណាទេ ស្រណោះកូន កំហុសរបស់គាត់ គាត់សុខចិត្តងាប់តែគាត់ចុះ ឲ្យកូនប្រពន្ធរស់។ បើយើងរត់ខ្លាចគេធ្វើបាបប្រពន្ធ កូន។

ប៊ុនថន : ប៉ុនគាត់អត់មានធ្វើអីខុសទេ?

ធី : អត់មានខុសអីទេ មនុស្សស្លូតមិនចេះនិយាយ ជឹកស៊ីក៏មិនចេះស្លូតបំផុត។ ហើយគាត់ធ្វើទាហានតាំងពីជំនាន់ឥស្សរៈនោះ។ តាំងពីឥស្សរៈចូលស្រុកនោះ ជាង៣០ឆ្នាំ គាត់ស្លូតគាត់ធ្លាប់នៅវត្តនៅអីធ្វើកូនសិស្សលោកទៀត។

ប៊ុនថន : ចុះក្រោយៗមកទៀត?

ធី : ដល់បន្ទាប់មកម្ដាយមីងខ្ញុំក៏កូនងាំមួយ គាត់ខ្លាចគេវ៉ៃចោលគាត់ខំទៅធ្វើការ ទុកកូនចោលអាកូនហ្នឹងក៏ដាច់ពោះ ដាច់បាយស្លាប់ទៅកូនងើត៣ខែ កូនប្រុស។ រៀបនឹងទៅគាត់លាកូនលាអីឡើងស្រួល កូនមាសឪពុក ពុកទៅហើយពុកមិនបានឃើញមុខកូនទៀតទេ។ ហើយគាត់ថា ឯងទៅហើយ ម៉េចមិនស្លៀកពាក់ខោអាវឲ្យស្រួល ស្លៀកខោខ្លីកន្សែងអីចឹង។ បានឡើងទៅស្លៀកពាក់អាវ ហៅទៅដល់ផ្ទះប្រធានភូមិ គេចងគាត់យកទៅ។

ប៊ុនថន : អ្វ! ម៉េចដែរបានគេ?

ធី : គេថាយើងអ្នករត់ទាហានសម័យ លន់ នល់ ។

ប្រុញ : ហ្នឹងឪពុករបស់ពូ?

ធី : ឪពុកបង្កើត។ ហើយក៏បាត់ជ្រៀបទៅ។

ប៊ុនថន : អីចឹងបងពូបាត់តែម្នាក់ទេ?

ធី : បាទ! បងប្រុសអាយុ២៣ កាលគាត់ស្លាប់។

ប្រុញ : បាទ! គាត់ឈ្មោះអីគេបងអ៊ឹ?

ធី : ធន ប៊ុនធឿន។ ឪពុកខ្ញុំឈ្មោះ ថាំ ធីម កូននោះឈ្មោះ ធឿន។

ប៊ុនថន : បាទ! អីចឹងស្លាប់អស់២នាក់?

ធី ៖ ស្លាប់អស់២នាក់ ដែលគេចាប់យកទៅ ។

ប៊ុនថន ៖ បងបង្កើតហ្នឹង?

ធី ៖ បាទ!បងបង្កើតមួយ ឪពុកមួយ ។ បើថាប្អូនៗសុទ្ធតែឈឺទាំងអស់ ជំងឺដាច់បាយហ្នឹង អត់បាយស៊ី ។

ប៊ុនថន ៖ ប៉ុន្មាននាក់ស្លាប់ហ្នឹង?

ធី ៖ ទាំងអស់២នាក់ ។ ប្អូនប្រុសទាំងអស់ អាមួយអាយុ២ឆ្នាំ អាមួយអាយុ៨ខែ ។

ប៊ុនថន ៖ ស្លាប់ជំនាន់?

ធី ៖ បាទ!ស្លាប់ជំនាន់ប៉ុល ពតហ្នឹង ។ ស្លាប់ឆ្នាំ ៧៦មួយ ស្លាប់ឆ្នាំ៧៨មួយ ។

ប៊ុនថន ៖ អីចឹងនៅពូ តែពីរនាក់ទេ?

ធី ៖ នៅខ្ញុំមួយ បងស្រីមួយ បងស្រីនៅឯភ្នំព្រឹកមួយគាត់ទៅនៅភ្នំព្រឹកនោះ នៅ៣នាក់ ។

ប៊ុនថន ៖ បាទ!ពូកូនទីប៉ុន្មានពូ?

ធី ៖ ខ្ញុំកូនទី៤ រាប់ទាំងបងស្លាប់ផងហ្នឹងកូនទី៤ ហើយប្អូនស្រីងាប់សម័យយួនទេ ។

ប៊ុនថន ៖ អីចឹងពូមានបានរៀនសូត្រដល់ថ្នាក់ណាដែរ លោកពូ?

ធី ៖ ខ្ញុំរៀនកាលពីសង្គមខ្ញុំដល់ថ្នាក់ទី៨ ។

ប៊ុនថន ៖ រៀននៅសាលាណាដែរ?

ធី ៖ រៀននៅសាលាបឋមសិក្សាព្រះនេត្រព្រះហ្នឹង ។

ប៊ុនថន ៖ ចុះពូមានបានរៀនបន្តទៀតទេពូ?

ធី ៖ អត់បានទេ ។ សម័យប៉ុល ពត អ៊ុះ!សម័យយួនចូលមកខ្ញុំអាយុ១៩ហើយ ពេញយុវជនហ្នឹងធំហើយអត់បានរៀនបានអីទេ ។

ប៊ុនថន ៖ ចុះពូឈប់រៀនឆ្នាំណា?

ធី ៖ ៧៥ រៀនទាល់តែបិទសាលាមុនអាពតរំដោះ១៧ មេសា ប្រហែលម៉ាខែ ។ បិទសាលាដែលអាពតចូលវ៉ៃភ្នំពេញក៏បិទសាលាឡើងម៉ាខែ បានក្រោយម៉ោបានសន្តិភាព១៧ មេសាហ្នឹង ។

ប៊ុនថន ៖ អីចឹងសន្តិភាពហើយពូទៅណា?

ធី ៖ មុនដំបូងនៅកុមារក្នុងភូមិ ដល់ក្រោយម៉ោគេបញ្ជូនទៅចល័ត ។

ប្រុញ ៖ គេជម្លៀសពូទៅណាវិញ?

ធី ៖ គេជម្លៀសទៅនៅស្រះ នៅភូមិស្រះខាងលិច ។

ប៊ុនថន : ជម្លៀសទៅទាំងអស់គ្នាពូ?

ធី : ជម្លៀសទៅទាំងអស់ គ្រប់ភូមិទៅទាំងអស់ ជម្លៀសទៅប្រហែលជាចំនួន២ខែបានមកភូមិវិញ ។ ដល់ចូលភូមិវិញគេអត់ឲ្យនៅក្នុងភូមិវិញទេ គេឲ្យទៅនៅបោយសំរោងនោះ ។

ប្រុញ : ជម្លៀសទៅស្រែះគេឲ្យធ្វើអីគេពូ?

ធី : គេឲ្យធ្វើស្រែ បើកុមារៗបោចវល្លិ៍តាអើក ពុកៗឲ្យភ្ជួរ កុមារឲ្យបោចវល្លិ៍ផង ឃ្វាលគោផង ម៉ែឲ្យជួយបោចវល្លិ៍តាអើកដែរ ។

ប្រុញ : ពីណាគេមេកងរបស់ពូកាលនៅស្រែះពូ?

ធី : មេកងស្លាប់បាត់ហើយ ឈ្មោះតាកៅ ប្រធានភូមិស្លាប់បាត់ហើយ និរតីម៉ោគេយកទៅវ៉ៃចោល ។ កាលហ្នឹងគេថា កម្មាភិបាលពាយ័ព្យនេះក្បត់ និរតីម៉ោវ៉ៃពាយ័ព្យចោលអស់មួយសារ ។

ប៊ុនថន : តាកៅ គាត់ប្រធានភូមិស្រែះពូ?

ធី : ទេ!ប្រធានភូមិ តាប៉ែននេះគេជ្រើសរើសថ្មីៗ បើប្រធានភូមិពីសម័យលន់ នល់ នោះតាអៀម តាហ៊ាមហ្នឹងគេផ្លាស់ចោល អាហ្នឹងប្រធានភូមិពីសម័យលន់ នល់ គេរើសសម័យនេះដាក់តាកៅ ។

ប៊ុនថន : អីចឹងតាហ៊ាម នោះគេផ្លាស់ទៅណាវិញពូ?

ធី : ផ្លាស់នៅក្នុងភូមិហ្នឹង មកដល់សព្វថ្ងៃក៏ស្លាប់ដែរ ស្លាប់មុនពួកនិរតី ។ បើគាត់នៅក៏មិនរស់ដែរ ប៉ុនគាត់ស្លាប់មុន កាលហ្នឹងប្រធានភូមិគេវ៉ៃចោល ។ មនុស្ស៥០នាក់គេវ៉ៃចោលតាឈឿង ចាប់យកទៅវ៉ៃចោល៥០នាក់ គ្រូបង្រៀនហ្នឹងបើមានចាប់វ៉ៃចោលបាត់ ។

ប៊ុនថន : បាទ!អីចឹងពូទៅនោះ បានតែ២ខែទេ កាលជម្លៀសទៅស្រែះហ្នឹង?

ធី : ២ខែ ជម្លៀសឲ្យមកនៅនេះវិញ នៅតាមភូមិវិញ ។

ប៊ុនថន : អីចឹងកាលហ្នឹងអត់ទាន់មានចែកឲ្យហូបរួម ហូបអីទេ?

ធី : ហូបតាមផ្ទះ ប៉ុនបើកឲ្យម៉ាគ្រួសារ២កំប៉ុង ។ ដល់មកដល់ភូមិនេះបានវ៉ៃរបប២កំប៉ុងដដែល ដល់យូរៗទៅបាននិរតីម៉ោ បានមួយថ្ងៃកន្លះកំប៉ុង ស៊ីបាយរួម ។

ប៊ុនថន : ២កំប៉ុងហ្នឹង ប៉ុន្មាននាក់គ្រួសារពូ?

ធី : ក្នុងមួយនាក់គេឲ្យ២កំប៉ុង គ្នា៥នាក់បាន១០កំប៉ុងហើយ ។

ប៊ុនថន : អីចឹងហូបឆ្អែតដែរពូ?

ធី ៖ បាទ! ឆ្អែត ដល់ឆ្នាំ៧៥-៧៦ គ្រប់គ្រាន់ជីវភាពអត់ហូបបាយរួមទេ ដល់ចូល៧៧បាយរួម ។

ប៊ុនថន ៖ អីចឹងពូចេញពីស្រែះនេះ ម៉ោតាប៉ែននេះបានគេបែងចែកចូលកងពូ?

ធី ៖ អត់ទេ! រៀបកងពីនោះម៉ោ ។

ប៊ុនថន ៖ រៀបកងពីស្រែះមក?

ធី ៖ យកកងមកនៅនេះ មកនៅប៉ោយសំរោងអត់មាននៅនេះទេ ។ ប៉ោយសំរោងសុទ្ធតែ រែក១ចាន រែកឆ្នាំង អត់ឡូបរទេះទេ រែកកន្ទេល រែកខ្មើយ យោធាគេដើរតាមពីក្រោយ ខ្ញុំឃើញយោធាខ្លាចមិនហ៊ានមើលមុខគេទេ ឆ្វេកដើរទៅមុខចេះ ។

ប៊ុនថន ៖ ម៉េចបានខ្លាចចឹង?

ធី ៖ គេជិះកង់ កាំភ្លើងមិសាគៀល តែយើងហ៊ានវៃចោល ឲ្យវៃឃើញនឹងមុខ ។

ប៊ុនថន ៖ មានទេ មានវៃ?

ធី ៖ ទៅហ៊ាន វៃចោល កំពុងតែបរទេះអីចឹងវៃ ឃើញស្រះកើតទាំងប្រពន្ធទាំងកូនវៃចោលឲ្យឃើញមុខ ។

ប៊ុនថន ៖ មាន១វៃ?

ធី ៖ អឺ! ជំទុកយឿននោះ វៃចោល ដូចគេបរទេះវៃឃើញស្រះកើតទាំងកូន ។

ប៊ុនថន ៖ វៃឃើញនឹងភ្នែកម៉ង?

ធី ៖ វៃឃើញនឹងភ្នែក គេដាក់ផុស១ ។

ប្រុញ ៖ ឈ្មោះអីគេ?

ធី ៖ ជំទុកយឿន ជំទុកទី១ ស្លាប់នឹងកូន ។

ប៊ុនថន ៖ ជំទុកសម័យលន់ នល់?

ធី ៖ ជំទុកសម័យលន់ លន់ ។

ប៊ុនថន ៖ ជំទុកឃុំខាងព្រះនេត្រព្រះ?

ធី ៖ បាទ! ឃុំព្រះនេត្រព្រះ ខ្ញុំឃើញគេបរទេះមកពីក្រោម គ្រាន់តែឃើញហៅវា អ្នកណាគេបរកុំមើលគេបរឲ្យលឿន ខំវៃគោបំបោល ។

ប៊ុនថន ៖ ខាងណាគេវៃ?

ធី ៖ ដឹងអ្នកណាគេវៃ គ្នាគេ ដឹងជាទ័ពណា ។

ប៊ុនថន ៖ មានកាំភ្លើងមានអី?

ធី ៖ មានកាំភ្លើង មានស្រី មានប្រុស៣-៤-៥នាក់បណ្ដើរទៅ ប្ដីប្រពន្ធកូនគេដាក់ឡើងកំភួស ។

ប៊ុនថន ៖ យកអីវៃ?

ធី ៖ ចប ។

ប៊ុនថន ៖ ចប?

ធី ៖ បាទ! បើកកូនសាំចេះលើកភើមស្រី ទាញពីដៃបោះទៅលើកដោតជំពុះទង់ពីក្រោមជីបផាប់ផ្ទង ។ខ្ញុំឃើញឡើងព្រើលខ្លួនហើយឡើងរងារ យប់ឡើងដេកមិនលក់ទេ ភ័យខ្លាច ។

ប៊ុនថន ៖ ចឹងសម្លាប់នៅមុខប្រជាជនដម្បៀសនឹងពូ?

ធី ៖ យកពីភូមិទៅនៅតាមជំរំម៉ាភូមិៗ គេទៅនៅកាប់មែកឬស្សី មែកឈើធ្វើខ្នមនៅប្រក់ស្លឹកត្នោតចេះ ធ្វើខ្នមនៅតូចៗម៉ាជ្រកដូចរោងគោចេះ ធ្វើខ្នមនៅ ។ យើងធ្វើគ្រែនាមឬស្សីដេក សង់ដេកទៅ ។

ប៊ុនថន ៖ ពេលសម្លាប់គាត់ សម្លាប់ពេលពូដម្បៀស?

ធី ៖ ខ្ញុំបរទេះមកពីក្រោយ បរទេះមកឃើញ គេហៅជិះពីក្រោយថា ឡើងឲ្យលឿនៗកុំមើលគេខំបរទេះបំបោលវៃគោបំបោលរត់ឡើង ចុះចំងាយប្រហែលជា២០០ម៉ែត្រវាលស្រឡះទេ ។

ប៊ុនថន ៖ ចុះពេលពូឃើញ?

ធី ៖ ចុះបណ្ដើរៗទៅកាន់ចប ដាក់ពុះៗទៅដួលព្រុស ។

ប៊ុនថន ៖ ចុះអ្នកដែលវៃមានឃើញពូ បានឃើញ?

ធី ៖ ដែលទៅឃើញធ្វើ បើគេមិនដែលទៅនិយាយរកយើង បើគេយោធា ។

ប៊ុនថន ៖ អត់ខ្លាចគេចាប់ពូទៅទៀតទេ?

ធី ៖ ទេ! អានោះយើងមានកំហុសអីបើយើងមកពីស្រែ អត់ខ្លាចទេ យើងបរទេះមកពីស្រែ ។

ប៊ុនថន ៖ ច្រើនគ្នាទេ ឃើញវៃនឹង?

ធី ៖ ឃើញឡើង៤-៥ ម៉ោពីប៉ោចវល្លិ៍តាអើក គេឲ្យទៅប៉ោចវល្លិ៍តាអើក ។

ប៊ុនថន ៖ ចឹងវៃហើយសាកសពនឹង គេយកទៅណាវិញពូ?

ធី ៖ យកទៅឲ្យអ្នកស្រុកទៅកប់ទៅ កប់ចោល ឲ្យអ្នកស្រុក គេវៃរួចប្រាប់ប្រធានភូមិគេឲ្យចាត់កម្លាំងទៅកប់ចោល ។

ប៊ុនថន ៖ ប៉ុន្មាននាក់ថាវៃ?

ធី : ថាកូនចៅប៉ុន្មាន ជំទុកឃឿន កូន៤-៥នាក់ដឹង អាតូចអាធំប្រពន្ធប្ដី ។

ប្រុញ : វៃចោលទាំងគ្រួសារ?

ធី : ហ្នឹងហើយទាំងគ្រួសារ ដាក់ស្ដែងណាស់ឃើញគួរខ្លាចព្រើលក្បាល ។ បើលោកវ៉ៃដង បាញ់ខាងលិចវត្តពោធិ៍ ខ្ញុំដើរទៅឃើញថ្ងៃចេះ ឃើញកាន់ដំបងមួយជាមួយស្បែកជើងម៉ា សម្រាប់ ។

ប៊ុនថន : ឃើញសាកសពគាត់?

ធី : លោកវ៉ៃនឹង ទាហានលន់ នល់ សក្តិ២ បាញ់ចោល ស្រុកចប់ភ្លាម គេឲ្យជម្លៀសទៅ គេស្ទាក់បាញ់តាមផ្លូវ គេចាប់វ៉ៃ គេស្ទាក់ចាប់តាមផ្លូវស្រែះលិច គេវ៉ៃចោលទាំងប្ដីទាំងប្រពន្ធ ។ កាលនោះឲ្យតែអ្នកធំ សុទ្ធតែពិបាកវ៉ៃចោលអស់ ។

ប៊ុនថន : បាញ់នៅមុខពួម៉ុង ហើយក៏?

ធី : បាញ់ងាប់មុន ពួកខ្ញុំបរទេះចេញទៅដង្ហែរគ្នាដើរបរទេះទៅឡើងរអើកជម្លៀសចេញ ។

ប៊ុនថន : ទៅបានឃើញគាត់ស្លាប់?

ធី : ទៅឃើញដេកកើយលើទ្រូងគ្នា លោកវ៉ៃ ឃើញស្គាល់ហើយលោកវ៉ៃ ចុះខ្ញុំធ្លាប់ទៅរៀនបន្ទាយ នៅជិតសាលារៀន ផ្ទះនៅខាងផ្សារលក់ដូរសព្វថ្ងៃនេះបន្ទាយទាហានគេ សាលារៀននៅជាប់នោះឯង ធ្លាប់ឃើញគេវ៉ៃកាន់ដំបងម្ជួកគាត់ជានាយទាហាន ។ លោកវ៉ៃនោះពូកែណាស់បាញ់មិនឆេះ ម៉េចបានជាត្រូវងាប់ ។ តាមថា មុនដំបូងបាញ់អត់ឆេះទេ ស្ដោះទឹកមាត់ កោសអណ្ដាត.... ។

ប៊ុនថន : ពូកែចឹងម៉ង?

ធី : នឹងពូកែ ទាហាន អ្នកណាហ៊ានទេ ពូកែតែកងលោកវ៉ៃ ខ្លាចឡើងរួញ ម៉េចបានជាបាញ់ងាប់ អាគេបាញ់អត់ចេញ ស្ដោះទឹកមាត់ ចង់បាញ់ឯងលើកក្រោយដាក់ ស្ដោះទឹកមាត់អត់ទៀត ដុសអណ្ដាតកាស គ្រាន់តែឃើញគួរឲ្យខ្លាចនាយទាហាន ។

ប៊ុនថន : ខាងលន់ នល់នឹង?

ធី : បាទ!ខាងលន់ នល់ ។

ប្រុញ : កាលដែលពូទៅធ្វើនឹងហើយ គេឲ្យពូទៅធ្វើនៅត្រពាំងថ្ម?

ធី : បាទ! រួចខ្ញុំចល័តច្រើនណាស់ ចល័តកំបោរ លើកស្រែះនេះរួចទៅស្វាច់ៗរួចបានទៅព្រៃកប្បាស កងវ៉ា ទៅកាប់ព្រៃ ។ កងវ៉ានេះសុទ្ធតែព្រៃ ភ្នំបាក់ជីឡូត៍គីឡូកងវ៉ានឹង ទម្រាំតែទៅកំរៀងបាន ។

ប៊ុនថន ៖ ចុះដំបូងពូចេញទៅធ្វើនៅណា?

ធី ៖ ទំនប់កំបោរ ។

ប៊ុនថន ៖ ហ្នឹងពូចូលកងហើយ?

ធី ៖ បាទ! ចូលកងកុមារហើយ សុទ្ធរែកម៉ែត្រគីប ម្នាក់២ម៉ែត្រគីប ។

ប៊ុនថន ៖ ពីណាប្រធានកង?

ធី ៖ នែក! ប៊ុ ជន តាខេង កងតូចកងធំ ។

ប៊ុនថន ៖ ជននឹង អ្នកភូមិណាដែរ?

ធី ៖ អ្នកត្រឡោក ភូមិត្រឡោក ។

ប៊ុនថន ៖ នៅស្រុកព្រះនេត្រព្រះដែរ?

ធី ៖ ស្រុកព្រះនេត្រព្រះ ប៉ុនឃុំភ្នំលាភ ដល់តាជន នឹងងាប់ទៅ កើតទឹកនោមផ្អែមងាប់ទៅបាន ឡើងតាស្រៀប តាខេង ប្រធានកងធំ ។

ប៊ុនថន ៖ សព្វថ្ងៃគាត់នៅរស់ដែរ ប៉ុន្មាននាក់?

ធី ៖ នៅធ្វើគ្រូដឹង តាខេងនៅធ្វើគ្រូ ។

ប៊ុនថន ៖ គ្រូនៅណាវិញ?

ធី ៖ គ្រូបឋមនៅភ្នំលាភ ឃើញខ្ញុំចេះ សើចដាក់ញញឹម ។

ប៊ុនថន ៖ តាខេងនឹង ប្រធានកងធំដែរ?

ធី ៖ ប្រធានកងធំ ។ ស្រៀបនោះកងធំដែរ ។

ប៊ុនថន ៖ ស្រៀបនឹង គាត់នៅណា?

ធី ៖ នៅភ្នំលាភ ។

ប៊ុនថន ៖ គាត់ធ្វើអី?

ធី ៖ គ្រូដែរ ស្រៀប ។

ប៊ុនថន ៖ គ្រូបឋម អនុវិទ្យាល័យ?

ធី ៖ គ្រូបឋម ប៉ុនស្រៀបនោះថាងាប់ហើយ សួរគេ សួរតាសេងថាងាប់ហើយ តាស្រៀប នៅតែតាខេង តាស្រៀបងាប់ហើយ ឈឺកើតជម្ងឺអីទេ ។

ប៊ុនថន ៖ គាត់នៅភ្នំលាភ?

ធី ៖ ភ្នំលាភ ។

ប៊ុនថន ៖ លោកពូទៅការងាររម៉ាថ្ងៃធ្វើប៉ុន្មានដែរ នៅកំបោរ ស្រះនឹង?

ធី : អូ! ក្រោកភ្លឺឡើងដីងថាបាយៗ៣ពេល ស៊ីរួចភ្លឺឡើងដីងចុះៗដល់ម៉ោង១១ស៊ីបាយថ្ងៃ រួចម៉ោង១ចុះទៀត ទាល់តែល្ងាចម៉ោង៥បានឡើងស៊ីបាយ ។

ប៊ុនថន : ហើយពេលយប់មានធ្វើទៀតទេ?

ធី : ពេលយប់ធ្វើ ដល់ម៉ោង៧ដល់ម៉ោង១០ ។

ប៊ុនថន : រាល់ថ្ងៃ ឬមួយម្ដងម្កាល ពេលយប់?

ធី : មុនដំបូងផែនការស្រាលអត់ទាន់នេះ ទាល់តែផែនការសម្រេចថាត្រូវយកម៉ាខែឲ្យរួចទាំង យប់ បុកទាំងយប់ទាំងថ្ងៃវាស់ម៉ែត្រគីប ។ មុនដំបូងសែងតែបង្គីរ១ ២នាក់ បានម៉ាខែ ឡើងវែកបណ្ដោយ បើត្រពាំងថ្មបានខ្លាំងមែនទែន ត្រពាំងថ្មទាំងយប់ទាំងថ្ងៃ ។

ប៊ុនថន : ចឹងនៅស្រែះនឹងធ្ងន់ៗទេ សម្រាប់ពូដូចថាធ្ងន់ធ្ងរទេ ២ម៉ែត្រគីបវែកហើយទេ?

ធី : ហើយ ជួនថ្ងៃណាហើយ ជួនថ្ងៃណាអត់ហើយ ស្រេចតែដីវីង ដីទន់ ដីរីងផុយតិចហើយ បើថាដីរីង ម៉ាថ្ងៃបានម៉ាម៉ែត្រគីបកន្លះទេ អត់រួចទេ ។

ប៊ុនថន : អត់ហើយម៉េចទៅ អត់ហើយ មានពិន័យ មានអី មានប្រជុំមានអី?

ធី : អត់ហើយ ពិន័យឲ្យស៊ីបាយម៉ាចាន ប្រជុំតិចទៀន ប៉ុនឲ្យស៊ីបាយម៉ាចាន បើអាណាលើក ហើយ បាយដាក់ឲ្យស៊ីម៉ាផ្អែត សម្លត្រីថែមឲ្យម៉ាផ្អែត បើថាអាក្រុមណាដូចថាធ្វើយឺត ធ្វើមិនសូវសកម្មការងារ មិនសូវខ្លាំង បាយតែម្នាក់ម៉ាចានទេ សម្លក៏ម៉ាចាន១០នាក់ អស់អានឹង ដាក់អំបិលម៉ាក្ដាប់ឲ្យពងត្រីសៗ ។ បើថាហ៎! អស់សម្លហើយ សុំសម្លទៀត មិនមាន ទេពងត្រីសខ្វះអី ដាក់អំបិលម៉ាក្ដាប់ឲ្យស៊ីទៅ ។

ប៊ុនថន : ចឹងនិយាថា ដកតែរបបអាហារទេ អត់មានដាក់ពិន័យផ្សេងទៀត?

ធី : អត់ទេ បើទំនប់ត្រពាំងថ្មបានខ្លាំង ត្រពាំងថ្មបើអ្នកណាហានឈឺជាប់តែ៥ថ្ងៃ អូសដៃទៅ ធ្វើការហើយ សុទ្ធដាក់៣ម៉ែត្រគីបហើយ ដាក់បង្គីប៉ុនៗនេះ បុកដាន់ទៀត វែកមិនរួច មានអាអ្នករុញគូទទៀត មានអ្នករុញគូទវៃពីក្រោយទៀត វែកឲ្យឡើងឲ្យរួច ឃើញតែ វែកតែសតាស សឹងងាប់សឹងរស់ធ្វើបាប អានោះផែនការខ្លាំង ។

ប៊ុនថន : អីចឹងពូនៅខាងកងកុមារភ្នំស្រែះហ្នឹង ដូចថាកុមារមានច្រើននាក់ទេពូ ធ្វើការនៅហ្នឹង?

ធី : ចូលប្រហែល២០០នាក់ ៣កងធំ មួយកងធំ៧០នាក់ ។

ប៊ុនថន : បាទ!៣កងធំ២០០នាក់ដាង?

ធី : បាទ!ដាង២០០នាក់ ។

ប៊ុនថន : ហើយកុមារភាគច្រើនពីអាយុប៉ុន្មានដល់អាយុប៉ុន្មានពូ?

ធី : បើដកពីភ្នំស្រុកកុមារកំព្រាគេបញ្ចូលមកកាលនោះ ត្រពាំងថ្មមានអាយុ៦ឆ្នាំ ប៉ុនកូនខ្ញុំមីង ស្រីនាង ហើយអាកូនតូចកូនងើតតូចៗឈ្មោះអាស្រី អាហុង។ អាហុងហ្នឹងកូនយួនទៀត តែហៅស៊ីបាយ«អាំងកើម»ម៉ែឪវាគេយកទៅវ៉ៃចោលអស់ យកទៅដាក់កុមារកំព្រា។

ប៊ុនថន : តែនៅរស់ទេម្នាក់ហ្នឹង?

ធី : នៅរស់តែមិនដឹងទៅខាងណាទេ។

ប៊ុនថន : គេអត់នេះដែរ?

ធី : គេអត់ធ្វើបាបទេ ទូលតែទៅលើចេះ បើអាយុត្រឹម៤-៥ឆ្នាំទេ។

ប៊ុនថន : អត់ចេះខ្មែរទេ?

ធី : មុនដំបូងចេះតែ«អាំងកើម»ស៊ីបាយប៉ុណ្ណឹងឯង។ ហៅវាច្រើន ដល់យូរៗទៅចេះ ស ស្លូសដូចគាត់អីចឹង ប៉ុនអានោះមិនដឹងបែកគ្នាទៅ ដល់ស្រុកចប់អីចឹងមិនដឹងថាទៅខាងណា ទៅខាងណីទេ។ ហើយអាអូនតូចមួយពោះកំប៉ោង គូទងរ ប៉ុនកូនខ្ញុំអាតុចមិញហ្នឹងជិះកង់ ៤ឆ្នាំ ៥-៦ឆ្នាំសុទ្ធកុមារកំព្រា ងាប់ម៉ែឪដែលគេបញ្ជូនពីភ្នំពេញមក ជម្លៀសមកអ្នកថ្មី ឆ្នាំ៧៦គេជម្លៀសមកម៉ែឪគ្មានពេលមើលទេ យកមកដាក់នៅកុមារកំព្រា ដល់ពេលនេះ គេជម្លៀសអាកុមារកំព្រាដាក់ចល័ត កាលហ្នឹងនៅក្នុងក្របខ័ណ្ឌចល័តតំបន់។ កាល សម័យនោះកុមារគេមិនសូវធ្វើបាបទេ គេថាកុមារទំពាំងស្នងឫស្សី។

ប្រុញ : ចុះពូនិយាយមិញថា កុមារឈ្មោះ រី ដែលពូថាម៉ែឪគាត់ជនជាតិវៀតណាមនោះ?

ធី : ឈ្មោះ ហុង។

ប្រុញ : ម៉ែឪគាត់គេសម្លាប់ដោយសារអីគេ?

ធី : ខ្ញុំមិនដឹង។ សួរវាមិនដឹងទេ ប៉ុនបើអ្នកនៅជាមួយគេថា ម៉ែឪវាគេសម្លាប់នៅឯភ្នំពេញ នោះ។ គេជម្លៀសតាមរតេភ្លើងម៉ោ ហៅវាអាហុង ស៊ីបាយ វាស្រែកថា«អាំងកើមៗ» វាដឹងតែវាកូនយួន វាចេះតែអាំងកើមទេ អត់ទាន់ចេះអីទេ។ ចុះវាទីម៩ឆ្នាំហ្នឹង ដល់នៅ បានមួយឆ្នាំបានវាចេះភាសាស៊ីបាយ ។

ប៊ុនថន : អីចឹងពូខ្ញុំត្រឡប់ទៅក្រោយវិញ ពូនៅកំបោរស្រះហ្នឹងបានយូរទេពូ ប៉ុន្មានខែ?

ធី : ៦ខែគត់ ពីខែ១ដល់ខែជេស្ឋ ៦ខែនៅលើកទំនប់នេះ។

ប៊ុនថន : បាទ!កាលហ្នឹង៧០ប៉ុន្មាន?

ធី : ឆ្នាំ៧៦ ។

ប៊ុនថន : ពូចេញពីហ្នឹងទៅណា?

ធី ៖ ទៅស្នាច់ៗបាក់ខែង លើកអានោះប្រហែល៣ខែរួច លើកទាំងខែភ្លៀងហើយ អានោះលើកប្រហែល២ខែកន្ទះ ។

ប៊ុនថន ៖ ស្នាច់ហ្នឹងលើកទំនប់ដែរពូ?

ធី ៖ ទំនប់ឡើងតាប៉ិង អាហ្នឹងនៅទល់សព្វថ្ងៃ ខ្ញុំទៅឃើញកាលហ្នឹងអនុស្សាវរីយ៍ខ្ញុំហើមដែរ ។ កាលហ្នឹងក្ដៅ ហើមទៅពេទ្យ២ថ្ងៃមកវិញ ទៅធ្វើការ បើថានៅដេកនេះងាប់ ឈឺក្រោកមិនរួច ស៊ីបបរក៏មិនកើត ហុតតែទឹក ។

ប៊ុនថន ៖ ឈឺអីវិញ?

ធី ៖ គ្រុនក្ដៅ ដល់ក្ដៅៗឡើង ផឹកតែទឹកវាហើម ។ ដល់ទៅនៅទំនប់កងវ៉ា គ្រុនញាក់ទៀត ក្ដៅផង ញាក់ផង ។

ប៊ុនថន ៖ អីចឹងកាលហ្នឹងឈឺទៅព្យាបាលនៅណា?

ធី ៖ យកមកពេទ្យស្នាច់.......... ។

ប៊ុនថន ៖ ឥឡូវនៅណាវិញស្នាច់ហ្នឹង?

ធី ៖ ស្នាច់បាខែង ចុះពីភូមិបេកនេះដល់ស្នាច់ ។

ប៊ុនថន ៖ នៅភូមិឃុំអីដែរ សព្វថ្ងៃនេះ?

ធី ៖ ឃុំទឹកជោរ អ៎!ស្នាច់មិនដឹងនៅភូមិអីទេ ភ្លេចទៅ វានៅជិតខាងភ្នំស្រុក ។

ប៊ុនថន ៖ ប៉ុននៅក្នុងស្រុកព្រះនេត្រទេ សព្វថ្ងៃ?

ធី ៖ អត់ទេ! ខងស្រុកភ្នំស្រុក ។

ប៊ុនថន ៖ ហើយមន្ទីរពេទ្យហ្នឹងមានអ្នកឈឺច្រើនទេ?

ធី ៖ ឈឺទាំងប្រុស ទាំងស្រី ទាំងកុមារាកុមារីងាប់តែរទូត ។

ប៊ុនថន ៖ ភាគច្រើនឈឺអីវិញ?

ធី ៖ ច្រើនតែគ្រុនក្ដៅភាគមួយ គ្រុនក្ដៅគ្រុនញាក់ភាគមួយ ហើយនឹងហត់ៗ ជួនក្ដៅ ជួនហត់ភាគមួយ ហើមឈឺគ្រប់តែគ្នា ។

ប៊ុនថន ៖ បាទ!ហើយថ្នាំព្យាបាលមានថ្នាំអីដែរ?

ធី ៖ មានតែថ្នាំអាចម៍ទន្សាយហ្នឹង យកទៅសូន្យដាក់ស្មៅសេះដាក់អីលាយទៅ លេបទៅខ្វះក៏ខ្ពួតមកវិញល្មីងស្មឹកឈើ ។

ប៊ុនថន ៖ ប៉ុននៅស្នាច់ហ្នឹងគេហៅមន្ទីរពេទ្យអីវិញពូ មន្ទីរឃុំ មន្ទីរពេទ្យស្រុកឬមន្ទីរអីវិញ?

ធី ៖ ឃុំរោគហ្នឹងឯង សម័យនោះឃុំរោគ ប៉ុនសម័យប៉ុល ពតគេយកវត្តមកធ្វើមន្ទីរពេទ្យ ។

ប៊ុនថន ៖ បាទ!គេហៅពេទ្យភូមិ ពេទ្យឃុំឬពេទ្យអីវិញ?

ធី ៖ ពេទ្យចល័តតំបន់ នៅវត្តស្នាច់ហ្នឹង ។

ប៊ុនថន ៖ នៅចល័តតំបន់ប៉ុន្មានពូ?

ធី ៖ នៅតំបន់៥ និយាយពីងាប់កប់តាមមាត់ស្ទឹង ។

ប៊ុនថន ៖ ម៉េចបានពូដឹងថាពេទ្យហ្នឹង ពេទ្យតំបន់?

ធី ៖ ចុះខ្ញុំទៅដេកពេទ្យហ្នឹង ខ្ញុំឈឺៗក្ដៅឡើងហើបៗ ។ កាលនោះដេក២-៣ថ្ងៃនោះបានចេញ ចេញគ្រុនទៀត ធ្វើការ១ថ្ងៃ២គេបញ្ជូនទៅទៀត បញ្ជូនបាន១ថ្ងៃ២ថ្ងៃចេញទៀត បើនៅនោះងាប់(ស្ដាប់មិនបាន)ងាប់ ឈ្មោះអារីនៗ ។

ប៊ុនថន ៖ ឈឺអីវិញពូ?

ធី ៖ គ្រុនក្ដៅ បើខ្ញុំគ្រុនក្ដៅហើយហើម ។

ប៊ុនថន ៖ ធំទេមន្ទីរពេទ្យហ្នឹង?

ធី ៖ រាងធំគ្រាន់បើដែរ ទទឹងប្រហែលជា១៥០ម៉ែត្រ បណ្ដោយ អូ!ម៉ាបរិវេនធំគ្រាន់ដែរ វត្តដែលតូច ជំរៅប្រហែល៥០ម៉ែត្រ៤ជ្រុង ហើយអ្នកជំងឺគេដាក់នៅតាមសាលាឆាន់ តាមវិហារ តាមកុដ្ឋអី លោកអត់មានទេ លោកសឹកអស់ហើយ អត់មានលោកទេ ។ ដាក់ទៅអាណាដេកលើដេកទៅ អាណាដេកដីក៏ក្រាលបាវដេកទៅ ការុងបាវ មិនដែលមានកន្ទេលអី ដេកទៅក្រោកមិនរួចដេកហៀរអាចម៍តែប៉េះ ។ បើងាប់ទៅ គេយកយកបាវមកក្របៗដាក់សែងទៅ មានអាអ្នកដើរចែកបាយ មានពេទ្យគេដើរបំរើអ្នកជំងឺដើរចែកបាយ ពេទ្យថាអ៎!ខ្មោចងាប់ហើយ លើកដាក់ក្នុងបាវដាក់ត្រែសសែងទៅកប់ ។

ប៊ុនថន ៖ កប់នៅណាវិញពូ?

ធី ៖ នៅតាមមាត់ស្ទឹង ស្ទឹងចេះដើរទៅកប់មាត់ស្ទឹងទៅ ។

ប៊ុនថន ៖ បាទ!ចុះអ្នកណាប្រធានពេទ្យពូមានចាំទេ?

ធី ៖ តាសុខ ប្រធានចល័តតំបន់ ។

ប៊ុនថន ៖ តាសុខ ហ្នឹងគាត់អ្នកស្រុកណាដែរពូ?

ធី ៖ អ្នកខាងតាកែវ ។

ប៊ុនថន ៖ ខាងនិរតីដែរ?

ធី ៖ បាទ!និរតីក៏ធ្វើយោធា ធ្វើចល័តជាមួយគ្នាឡើងវិតាមសមរភូមិទៀត កាលមុននៅដីក្រែង តែឥឡូវឈប់នៅនេះហើយ ។ ខ្ញុំឃើញយ៉ាស!ប្រធានពេទ្យ គាត់សើចគាសុខហ្នឹងប្រធានពេទ្យ ។

ប៊ុនថន ៖ កាលមុននៅដីក្រែង?

ធី ៖ បាទ!គាត់ប្រធានចល័តពេទ្យ សព្វថ្ងៃទៅនៅនោះហើយ(ឧត្តរមានជ័យ) បានប្រពន្ធទៅនៅឧត្តរមានជ័យប្រពន្ធច្រើនណាស់ ដល់គាត់រត់ក្លាម កាលពីសម័យនោះគេធ្វើតែកម្មករលីបាវ ដល់ពេលលីៗទៅក៏ឈប់មកធ្វើពេទ្យទាហាន ។ ដល់ឈប់ពីពេទ្យទាហានមកដើរដឹកដើរអី សព្វថ្ងៃនេះបានប្រពន្ធនៅឧត្តរមានជ័យឈប់ដើរទៅ ។

ប៊ុនថន ៖ កាលហ្នឹងគាត់ធ្វើពេទ្យ?

ធី ៖ ទាហានពេទ្យចល័ត ពេលប្រជុំម្តងៗហ៊ូ!គេស្រែក ប៊ុននិយាយកំប្លែងអស់ទាស់ ។

ប៊ុនថន ៖ បាទ!ស្លាប់ច្រើនទេ នៅពេទ្យហ្នឹង?

ធី ៖ អ៊ូ!ងាប់រាល់ថ្ងៃៗ ២-៣ថ្ងៃងាប់ ១ថ្ងៃ ២ថ្ងៃងាប់ ជួនណាក៏កប់ព្រឹក២អីចឹង ល្ងាច១ទៀតទៅ ស្អែកឡើងក៏១ទៀតទៅសែងទៅកប់ ។ ដេកនៅដី ជួនណាយើងទៅកាប់អាឈើមូលៗប៉ុននេះ ឈើក្រឡយើងដេក វារកិតខ្នងស្រគាដល់ហើយ ចុះឈើមូលៗប៉ុននេះដើមត្របែក ដើមរាំង ក្រាលបាវទៅ ជួនណាអត់មានបាវ អាក្អួយដណ្តប់ហ្នឹងក៏ក្រាលដេកទៅ ឈឺពេកឲ្យតែថ្នាំហ្នឹងដាក់ទៅ អាជាមិនជា អាត្រជាក់នៅតែក្តៅខ្លួនហ្នឹង តាមដំណើរទៅ ងាប់ទៅយកទៅកប់ គ្មានថ្នាំសារ៉ូម គ្មានថ្នាំណាចាក់ បើចាក់ៗទឹកដូង ។

ប៊ុនថន ៖ អ្នកជំងឺម៉ោពីណាខ្លះពូ ដេកពេទ្យហ្នឹង?

ធី ៖ ម៉ោពីចល័ត តាមអង្គភាព ។

ប៊ុនថន ៖ ចល័តម៉ា?

ធី ៖ ចល័តម៉ាតំបន់៥ហ្នឹង យុវជនផង នារីផង កុមារាផងកុមារីផង ។

ប៊ុនថន ៖ ពូការងារនៅស្នាច់ហ្នឹងគេមានកំណត់ឲ្យធ្វើទេ?

ធី ៖ គេវាស់ម៉ែត្រគីប ។

ប៊ុនថន ៖ ប៉ុន្មានម៉ែត្រគីប?

ធី ៖ ២ម៉ែត្រគីបកន្លះ ៣ម៉ែត្រគីបអ្នកធំ កុមារវ័យជំទង់ កុមារវ័យតូចមានអា២ម៉ែត្រគត់ក៏មាន ។ អាវ័យជំទង់អាធំៗអាយុ១៧-១៨ សុទ្ធតែ៣ម៉ែត្រគីប ។

ប៊ុនថន ៖ រអីចឹងចង់ស្មើគ្នាជាមួយកងចល័តយុវជនដែរ?

ធី ៖ យុវជន៤ម៉ែត្រគីបទៅ៥ម៉ែត្រគីប ។ ឆ្នាំ៧៧ ផែនការខ្លាំង តាវ៉ាល់ខ្លាំងពេលប្រជុំម្ដងៗ ស្រែកអ៊ូ!អស់ស្អុះហើយ ។

ប្រុញ ៖ ពេលពូចេញពីស្ទាចទៅ ទៅណាវិញ?

ធី ៖ ទៅធ្វើចំការកប្បាសកងវ៉ា កាប់ព្រៃ ដេកហាលភ្លៀង កាប់ត្រង់នេះដេកត្រង់នេះឯង ក្រោកយកដាក់ភ្លើងស្វាកាប់ ។

ប៊ុនថន ៖ កាប់ទាំងយប់ទៀត?

ធី ៖ កាប់ផ្ទាក់ទាំងយប់ អាកងវ៉ាកងពិសេសនោះសម្រាប់ឆ្ការព្រៃកាប់នឹងចប ឈើប៉ុនៗនេះ ។ អាកងស្មើដើង គេហៅអាកងរាបស្មើដើងហ្នឹង កងតូចៗមានតូចមានធំហ្នឹង អាហ្នឹងផ្ទាក់ដី ផ្ទាប់កាប់ដាំកប្បាស ផ្ទាក់បានហើយមានដាំ មានដាំហើយទាញខ្សែៗផ្ទាក់ដាំ ។ បាទ! ពយកហ្នឹងសុទ្ធតែព្រៃភ្នំកងវ៉ា ភ្នំបាក់ដៃឡូគីឡូកងវ៉ាហ្នឹងសុទ្ធតែព្រៃ ។ ដល់នោះគេសំរេចផែនការម៉ាខែឲ្យរួចនោះ ដល់ត្រាក់ទ័រ ២០គ្រឿងត្រូវជួយ ។

ប៊ុនថន ៖ ប្រហែលប៉ុន្មានហិចតា?

ធី ៖ ចូល១ពាន់ហិចតា ឲ្យត្រាក់ទ័រ២០គ្រឿងមកជួយ តាហ៊ីង ហ្នឹងមកជួយ បើត្រាក់ទ័រអត់ចុះ វ៉ាភ្លៀងចុះខែបិណ្ឌនោះ ភ្លៀងទាំងយប់ទាំងថ្ងៃ ភ្លៀងទាល់តែត្រាក់ទ័រចូលអត់ចុះ លេងតែចប ។ អ៊ូ!លេងបើនង្គ័លឡើងស្អិត ហើយរើរបបទៀត អាណាធ្វើលឿនជាងគេដាក់លេខ១ ក្រុមទី១ឲ្យស៊ីម៉ាផ្លែតត្រីប្រា ១៧០ស្លាបត្រីប្រា គេបើកឲ្យទៅស្ងោរ បេះតែស្ងោរៗតែម្ហូរ ស្ងោរដាក់ម្រេះព្រៅ ដីអំបិលទៅមានបិចេងណាបង់សម័យហ្នឹង ។ មើលអាណាធ្វើការលឿនរើដាក់ក្រុមទី១ ឲ្យស៊ីម៉ាផ្លែត បាយម៉ាផ្លែតសម្លម៉ាផ្លែតទៀត បើអ្នកណាធ្វើការឲ្យគេមិនសូវលឿន បាយតែម៉ាចានទេ សម្លម៉ាចានមានត្រីប្រាបេះឲ្យប៉ុនមេដៃ បើថាអ្នកធ្វើការលឿនដឹងតែស៊ី ម្នាក់ម៉ាផ្លែតៗហ្នង រើសដាក់ម៉ាក្រុមផ្សេង ។

ប៊ុនថន ៖ ចុះពូបានចូលក្រុមកងធ្វើការលឿនទេពូ?

ធី ៖ ខ្ញុំនៅតែក្រុមទី១រហូតៗ ខ្ញុំប្រធានក្រុមផង ក្រុមទី១រហូតប្រធានក្រុម ។ ចុះគេរើសអ្នកណាធ្វើការខ្លាំង កងតូចក្រុមទៅ បើយើងធ្វើការអែលៗខ្សោយជាងគេ ទៅថាឲ្យវ៉ាៗថាខ្លួនឯងធ្វើអែលៗនៅតែក្រោយគេ ថាឲ្យគេ ចាញ់ពាក្យវ៉ាអត់ហ៊ានថាឲ្យវ៉ាទេ ។ យើងការងារខ្សោយ យើងដឹកនាំកូនចៅអត់បានជឿលឿនទេ ទាល់តែយើងធ្វើខ្លាំងជាងគេ បើយើងធ្វើខ្លាំងជាងគេ បើអាណាធ្វើយឺតយើងសម្លុតឲ្យវ៉ាៗអត់ហ៊ានតឲ្យយើងវិញទេ វ៉ានៅក្រោយ បើយើងនោះដល់នោះវ៉ានៅនេះ កាប់ដី កាប់គីបៗនៅមុខ យកម្នាក់ម៉ា

ម៉ែត្រ ម្នាក់កន្ទះ យើងដឹងតែទៅមុនវាហើយ ណែ!ឯងធ្វើមិនលឿនល្ងាចឲ្យឯងស៊ីបាយតែមួយចាន សម្លមួយវែកឥឡូវឯងខំឲ្យលឿន វាខំវាខ្លាចដែរ ។

ប្រុញ : កាលហ្នឹងពីណាមេកងពូ?

ធី : មេកងស៊ីនួន មេកងតូច គាខេន នោះកងធំ(ស្រី) ។ ស៊ីនួន ប៉ុលសាវ៉ែនោះខ្ញុំឃើញយ៉ាស់! លោកប្រធាន គាត់សើចហេ៎ៗ! ។

ប៊ុនថន : សព្វថ្ងៃហ្នឹង?

ធី : ហ្នឹងហើយ ពួកអាង៉ែតនេះ ប្រធានកងតូចដែរ បើអាឆៅកនោះឲ្យធ្វើអនុប្រធានកងតូចឡើងរត់មកផ្ទះ(សើច) អាឆៅកខ្ជិលធ្វើតែខ្វាក់មាន់ ខ្ជិលធ្វើការយប់ ធ្វើជាលូកចានសម្ល ខុសទៅណា ដល់គេគាឲ្យខឹងរត់មកផ្ទះបណ្ដោយ ។

ប៊ុនថន : ប៉ុននៅចំការកប្បាសហ្នឹងការងាររអត់ធ្ងន់ដូចនៅកងចល័តទេ?

ធី : អត់ធ្ងន់ដល់វែកដីទេ វែកដីធ្ងន់ៗនោះបានយ៉ាប់ ។ ហ៊ានឈឺតែ៩ថ្ងៃអី មិនទៅធ្វើការវ៉ៃចោល កាលហ្នឹងវ៉ៃអាអាត អាស៊ីមហើយអាណាមួយទៀតទេ ៣នាក់ ។ គាស្រាប រាយការណ៍ ក្នុងម៉ាកងធំខ្ញុំមានតែ៣នាក់ទេ ដែលមិនដើរតាមសមរភូមិ ឡើងគាវ៉ាល់ ស្រែកមើល៎អាណាក៏ខ្ជាំងម៉្លេះយកមកឲ្យអញៗ អានោះវាឈឺអត់ទៅធ្វើការ នៅក្នុងខ្ទមអត់បានទៅប្រជុំ ។ ប្រជុំគេប្រាប់ថា អាអាត អញគេយកទៅហើយ គាវ៉ាល់ ឲ្យប្រធាមកងគេយកទៅឲ្យគាត់ហើយ វាស្រែកឡើងង្ហូងយំអោបសរសេររូង គេទាញគ្នា៣នាក់ថាឲ្យទៅចាំចំការឪឡឹកនៅជប់ ច្បាស់ជាងាប់ហើយមានគេប្រាប់ហើយ អ៊ូ!អានោះវាស្រែកយំអាស៊ីម អាអាតស្រែកយំអោបតែសរសេរ ទាញអូសទាញគ្នាច្រើនណាស់ ។

ប្រុញ : អ្នកណាគេអ្នករាយការណ៍ពូ?

ធី : ប្រធានអាស្រាបហ្នឹង ។

ប៊ុនថន : នៅរស់ទេពូ?

ធី : សព្វថ្ងៃពុគេងាប់ហើយ ពុគាសេង នោះថាងាប់ហើយ គាត់ឈឺលើសឈាមមិនដឹងស្អីទេខ្ញុំឃើញវ៉ៃ៣នាក់ហ្នឹង ។

ប៊ុនថន : វ៉ៃនៅមុខហ្នងពូ?

ធី : អេ៎!យកទៅស្វាត់ជ្រាប យប់ឡើងបិទអន្តប្រជុំ គេមកគេយកទៅ ។

ប៊ុនថន : ចុះពូនៅចំការកប្បាសហ្នឹងពីណាអ្នកគ្រប់គ្រងនៅហ្នឹង ដូចថាមើលនៅការដ្ឋានចំការកប្បាសហ្នឹង?

ធី ៖ តាវ៉ាល់ គាត់ប្រធាន ប៊ុនតាលីម នោះគាត់ខាងមើលការខុសត្រូវ ។

ប៊ុនថន ៖ ឈ្មោះអីលីមពូ?

ធី ៖ ឈ្មោះ តាលីម តាយន់ ។

ប៊ុនថន ៖ ហ្នឹងគាត់អ្នកមើលការខុសត្រូវនៅហ្នឹងហ្មង?

ធី ៖ បាទ!ពួកប្រធានវរៈ គាត់មេទាំងយុវជន ទាំងកុមារ ៣វរៈសេនាធំ ។

ប៊ុនថន ៖ ម៉ាវរៈ៣០០នាក់ពូ?

ធី ៖ បាទ!៣០០នាក់ ជួនណា បានតែ២០០នាក់ ២០០នាក់ជាង ខ្លះដេកពេទ្យរត់មកផ្ទះទៅ ខ្លះស្លាប់ទៅ ។

ប៊ុនថន ៖ ហើយទេពូធ្វើចំការកប្បាសហ្នឹង?

ធី ៖ ហើយ សម្រេចផែនការឡើងរួច ។ ដល់រួចទៅនៅជម្រុះស្មៅឡើងរួចទៀត ឆ្នាំជម្រុះស្មៅពួកខ្ញុំធំៗបេះគេឲ្យ បាញ់ថ្នាំ អាយុ១៧-១៨ហ្នឹងគេឲ្យបាញ់ថ្នាំ ។ បើតូចៗអត់ឲ្យបាញ់ទេ វាស្ពាយស្បោងអត់រួច បាញ់ថ្នាំលាយថ្នាំបាញ់ តូចៗឲ្យជម្រុះស្មៅ អាណាតូចៗជាងគេឲ្យដើរចាប់ដង្កូវ ចាប់មេអំបៅតាមកប្បាសហ្នឹង ដល់ពេលចប់ដល់ពេលបេះ ទៅប្រគល់ឲ្យសហជីបនៅភូមិគោកពន្រ បេះទៅពួកខ្ញុំត្រឡប់មកត្រពាំងថ្មនេះ មកលើកទំនប់នៅត្រពាំងថ្ម ។

ប៊ុនថន ៖ អាហ្នឹងគេថាម៉េចពូ ពេលដូរទៅត្រពាំងថ្មហ្នឹង?

ធី ៖ ទៅលើកទំនប់ ។

ប៊ុនថន ៖ ខាងណា?

ធី ៖ ចល័តតំបន់ហ្នឹងហើយ ដកមក ។

ប៊ុនថន ៖ គេថាទៅលើកទំនប់ហ្មង?

ធី ៖ បាទ!គេឲ្យយើងផ្លាស់ទៅសមរភូមិត្រពាំងថ្មហ្នឹង ប្រគល់កប្បាសហ្នឹងប្រគល់ឲ្យសហជីប ប្រជាជនអ្នកបេះទៅគេប្រមូលកប្បាសទៅយកទៅដាក់នៅភូមិគោកពន្រ ។

ប្រុញ ៖ ដល់ពេលម៉ោត្រពាំងថ្មពូនៅប្រធានក្រុមដដែល?

ធី ៖ ប្រធានក្រុម អនុក្រុម គេដកខ្ញុំយកមកដាំបាយ គេឃើញខ្ញុំស្គមពេក គេឃើញខ្ញុំដូចថាយើងនឿយពេក ម៉ាខែ៣០ថ្ងៃមិនដែលហ៊ានឈប់មួយថ្ងៃទេ មិនដែលហ៊ានឈឺទេ តែហ៊ានឈឺអាកូនក្រុមវាក៏សាងយើង ។ យើងដឹកនាំគេយើងម៉េចហ៊ានឈឺ អត់ហ៊ានឈឺទេ ទាល់តែប្រធានគេថា អ្ហូ!វាស្គមណាស់ដក ប្រធានក្រុមបើមិនធ្វើអីចឹង អត់ឈ្នះកូនក្រុម

ទេ ធ្វើការអត់លើកូនក្រុមទេ ដល់គេដកខ្ញុំឲ្យធ្វើចុងភៅដាំបាយ ដាំបាយស៊ីឆ្អែតហ្នឹង បាយក្តាំងសម្ងអីចុងភៅអីស៊ីមាំឆ្អែតៗ សម្ងបាយស៊ីមាំឆ្អែតៗ ល្ងាចឡើងដួសចែកតាមក្រុមទៀត មាំចានដែកៗម្នាក់ ដូចថាមាំក្រុម១០នាក់អីចឹង១០ចាន សម្ងមាំឆ្នាំងៗប៉ុននេះឲ្យទៀត ។

ប៊ុនថន : ប៉ុន្មានកំប៉ុងពូមាំក្រុម?

ធី : នៅរបប២កំប៉ុង ។

ប៊ុនថន : មាំក្រុម២កំប៉ុង?

ធី : ទេ! តែម្នាក់ហ្នឹង២កំប៉ុង ។

ប៊ុនថន : ម្នាក់២កំប៉ុង?

ធី : បាទ! ១០នាក់ ២០កំប៉ុង ។

ប៊ុនថន : ហើយប៉ុន្មានពេលលោកពូ?

ធី : ២ពេលទេ ព្រឹកល្ងាច ដល់ពេលសមរភូមិ៣ពេល ព្រឹកបបរ២កំប៉ុងកន្លះ បើសមរភូមិធម្មតាអត់បង្ហើយហ្នឹង២កំប៉ុង មានផែនការខ្លាំងផែនការស្រាល បើថាគេសម្រេចយកលឿនបុកទាំងយប់ទាំងថ្ងៃ២កំប៉ុងកន្លះ បើថាផែនការធម្មតាធ្វើតែថ្ងៃទេ អាហ្នឹង២កំប៉ុង ។ បើនៅកុមារហូបឆ្អែតហ្នឹង បើយុវជនស៊ីមិនឆ្អែតទេ យុវជនស្គមៗ ។

ប្រុញ : កាលហ្នឹងមេកងធំ មេកងតូចរបស់ពូពីណាគេ?

ធី : វាផ្លាស់ប្តូរចុះឡើង អាស៊ីនួនផង ដូនណាអាផែតៗ ។

ប្រុញ : ពេលនៅត្រពាំងថ្មដែលពូចាំច្បាស់ជាងគេ ពីណាគេ?

ធី : មេកងកាលនោះស៊ីនួន មេកងតូច ។

ប្រុញ : ចុះមេកងធំ?

ធី : មេកងធំតាស្រាប ហើយហើមជើងដើរមិនរួចឲ្យទៅរែកទឹក រែកទឹករែកមិនរួចបើហ្នឹងហើម ។ ដើរតងៗដើរលើកជើងមិនចង់ផុតពីដីផង ជិម្ពប់ជើងដួល អាទឹករលកជម្ពប់មកដល់ថាឲ្យទៀត ហែងចាក់ទឹកចោលអី ឲ្យដឹកទឹកក្តៅ ស្រុះសំបកស្តៅឲ្យដឹក លុំងដឹកក្អួតចាក់ចោល ស្ងោរដាក់សំបកស្តៅឲ្យដឹក រែកថាឲ្យធ្វើការស្រាល រែកទៅវាបាត់ហើម ឲ្យមកធ្វើការស្រាល រែកដើរជម្ពប់ទឹកនៅសល់តែកន្លះៗចាំង សម្មតឯងចាក់ទឹកចោលអីនេះ បានទឹកដាក់កន្លះៗ គេដឹកចេះ ដេញឲ្យឯងទៅយកទៀត រែកចុះរែកឡើងដើរទៅដើរមកដាក់តាមកន់គេ ។

ប៊ុនថន :	ចុះពូមានចាំថានៅត្រពាំងថ្មហ្នឹងគេធ្វើពីដំបូងបំផុតនៅឆ្នាំណាពូ?

ធី :	ពី៧៧ ខែ២ ។

ប៊ុនថន :	បាទ!ហើយអ្នកណាដែលមានគម្រោងឲ្យធ្វើហ្នឹង ដូចថាបួន?

ធី :	តាហ៊ិន ហ្នឹងឯង តាហ៊ិនថ្នាក់តំបន់ ។

ប៊ុនថន :	តាហ៊ិន ហ្នឹងគេមានប្រកាសថាធ្វើដើម្បីអីទេពូ?

ធី :	គេធ្វើអាងទឹក ទំនប់អាទឹកសម្រាប់ធ្វើស្រែប្រាំង ដល់ធ្វើរួចក៏ពួកខ្ញុំនៅធ្វើស្រែប្រាំងនោះ ១ឆ្នាំ ។

ប៊ុនថន :	បានប្រើប្រាស់ដែរ?

ធី :	បាទ!ធ្វើរួចគេឲ្យនៅមើលថែទំនប់ហ្នឹងឯង គេឲ្យទៅកាប់ឈើនៅកូនខែ្វងយកមកធ្វើរបងៗ ហើយរែកម្តក់យកមកដាក់ ។ ម្តក់ដាក់នៅតាមជើងទំនប់កុំឲ្យទឹករលកវាវៃបាក់ ហើយរបងចេះនេះយើងដាក់មែងឈើរាំងៗកុំឲ្យទឹករលកម៉ោកុំឲ្យវាបុកដាច់ បើថាដាច់ជើងទំនប់ភ្លាម ដែនការភ្លាមទៅទាំងយប់ រែកទល់ភ្លឺៗ ដល់ភ្លឺឡើងស៊ីបាយហើយចុះទៀតខ្លាចបាក់ទំនប់ បាក់ទំនប់ហ្នឹងសាប់អ្នកក្រោមអស់ លិចស្រូវលិចអង្ករទៅ ខ្វះឆាយស្មៅៗរែកយកទៅដាំ នៅតាមជើងទំនប់ខ្លាចវាបាក់នោះ..... ។

ប៊ុនថន :	ចុះពូតាហ៊ិនហ្នឹងគាត់?

ធី :	គាត់ចល័តតំបន់ ។

ប៊ុនថន :	ចុះរ៉ាល់?

ធី :	រ៉ាល់ហ្នឹងប្រធានចល័តតំបន់ សុទ្ធតែគ្នាគេហ្នឹង អ្នកម៉ោខាងភ្នំពេញ ខាងស្វាយរៀង ។

ប៊ុនថន :	ពីណាស្វាយរៀង?

ធី :	ពួកតារ៉ាល់ តាហ៊ិនហ្នឹង ។

ប៊ុនថន :	អីចឹងតាហ៊ិនហ្នឹងគាត់អ្នករៀបចំទំនប់ហ្នឹង?

ធី :	បាទ!រៀបចំដែនការហ្នឹង គេឲ្យបួន ។

ប៊ុនថន :	គាត់ខស្សាហ៍ចុះម៉ោទេ?

ធី :	ចុះម៉ោ គ្រាន់តែមាំលើកទំនប់មួយហ្នឹង មៅពាដងមកមើល កន្ទះខែមកម្តងៗ បើកឡាន មកៗឈប់នៅក្បាលទំនប់ស្ពានទី១នោះ គាត់ដើរមក តារ៉ាល់ គាត់ដើរមកមានថ្នាក់កម្មាភិបាលដើរអមគាត់... ។

ប៊ុនថន :	តាហ៊ិនហ្នឹង?

ធី ៖ តាហ៊ីងសស្កុសខ្ពស់ ហ្នឹងគាត់សំបុលជ្រះដែរ ។

ប្រុញ ៖ ចុះតាវ៉ាល់ គាត់អ្នកគ្រប់គ្រងនៅហ្នឹង?

ធី ៖ បាទ!អ្នកដឹកនាំកម្លាំងចល័តធ្វើការ តាហ៊ីងគាត់អ្នកមកត្រួតពិនិត្យមើល មានគម្រោងធ្វើ បេះៗឲ្យដែនការ ។

ប៊ុនថន ៖ ចុះក្រៅពីគាត់មានពីណាទៀតទេពូ?

ធី ៖ អត់ទេ ។

ប៊ុនថន ៖ ឮថាមានតាសន តាអីណាទៀត?

ធី ៖ តាសន ហ្នឹងវរៈសេនាធំ ។

ប៊ុនថន ៖ ប្រធានវរៈសេនាធំ?

ធី ៖ បាទ! ប៊ុនឯាប់អស់ហើយ និរតីម៉ោវៃចោលអស់ ស្រេះ អី ។

ប៊ុនថន ៖ តាណាទៀតពូ?

ធី ៖ តាស្រេះ ឲ្យតែកម្មាភិបាលតាវ៉ាល់ គេយកតាវ៉ាល់ទៅអស់ហើយ ក្រោយមកគេយក បោសសំអាតតាមក្រោយ បើកងធំអត់ធ្វើអីទេ កងធំកងតូចនៅ យកតែមេៗកំពូល ។

ប៊ុនថន ៖ បាទ!ចាប់ពីណាទៅពូ?

ធី ៖ ចាប់ពីផ្ទះថ្មហ្នឹង ។

ប៊ុនថន ៖ អត់ទេ ឋានៈចាប់ពីណាទៅ?

ធី ៖ វរៈសេនាតូចហ្នឹង ម៉ាវរៈសេនាតូចវាមាន៣កងធំ កងធំទី១ កងធំទី២ កងធំទី៣ មាន ប្រធានវរៈអនុវរៈទៅជាមួយគ្នា ។ ប្រធានទៅ អនុទៅជាមួយដែរ ទៅរៀនៗបាត់ ។

ប្រុញ ៖ ពីណាដែលហៅគាត់ថាទៅរៀនពូ?

ធី ៖ យោធា ជួនណាគេឲ្យសំបុត្រ យោធាជិះម៉ូតូមក គេដឹកទៅបណ្តោយទៅដឹកទៅបណ្តោយ គេថាយកទៅប្រជុំ ។

ប្រុញ ៖ អាហ្នឹងតាហ៊ីងអ្នកឲ្យម៉ោឬយ៉ាងម៉េច?

ធី ៖ ទេ!តាហ៊ីង ហ្នឹងគេយកវៃចោលអស់ហើយ និរតីមកតាហ៊ីង តាវ៉ាល់គេចាប់អស់រលីង តាម៉ោងអីចាប់ម៉ាត់សម័យហ្នឹង ពួកនិរតីមក ។ កាលហ្នឹងពួកតាស៊ីម តាយន់ តាពាល់ និរតី ។

ប្រុញ ៖ ពួកនិរតីមែនពូ?

ធី ៖ បាទ! កន្ទះខែប្រជុំៗ ចល័តរត់ឡើងចង់ពាយ និយាយរួមមិត្តយើងឃើញនៅកន្លែងស្រែ ត្រៀមរាល់ថ្ងៃ ត្រូវកន្លែងបំបាត់មុខ សស្រាក់សស្រាំនឹងការងារ និយាយរដើនៗដូចពួកអ្នកតាកែវ ។

ប្រុញ ៖ ពួកនិរតីមកមានឈ្មោះអីខ្លះពូ?

ធី ៖ តាយន់ តាពាល់ តាស៊ីមប្រធានចល័ត ប្រធានអនុប្រធាន កន្ទះខែប្រជុំៗ ។ ហ្នឹងលើកទំនប់រួចហើយៗ ហើយគេថាពួកតាវ៉ាល់ ក្បត់គេយកទៅវៃចោលអស់ទៅ គេចាប់យកទៅបាត់ស្ងាត់ជ្រៀបទៅ ដល់នេះបានពួកនិរតីមកឲ្យធ្វើស្រែប្រាំងបណ្ដោយ ។ ធ្វើស្រែប្រាំងខាងក្រោមពួកខ្ញុំដើរបើកទឹក បិទទឹក ស្ទូងមិនបានស្ទូងទេ កុមារគេឲ្យលើកភ្លឺ ប្រពន្ធ័ភ្លឺតូចៗកន្ទះម៉ែត្រ បើស្រីៗនារីៗឲ្យស្ទូង យុវជនស្ទូងដែរ កុមារគេឲ្យដើរបើកភ្លឺ ហើយបញ្ចេញបញ្ចូលទឹក ឃើញរុនកណ្ដុរអត់ហ៊ានកាយទេ តែកាយមួយយ៉ាប់វៃចោល ឃើញកណ្ដុររុនកណ្ដុរអីមានតែកាប់ដីបិទ រុនកណ្ដុរអត់ហ៊ានកាយទេ តែកណ្ដុរមួយកសាងភ្លាមឲ្យតែដល់ល្ងាចស៊ីបាយកសាង មិត្តឯងដឹកកណ្ដុរផ្ដាច់ភ្លឺផ្ដាច់អីទិទានយើងកសាង ។

ប្រុញ ៖ ចុះទំនប់ត្រពាំងថ្មហ្នឹងគេធ្វើហើយថ្ងៃខែឆ្នាំណាដែរពូ?

ធី ៖ ធ្វើចូលឆ្នាំរួច ខែពិសាខ ខែ៦ ចូលឆ្នាំរួច ។

ប្រុញ ៖ ឆ្នាំណាដែរពូ?

ធី ៖ ឆ្នាំ៧៧ ។

ជិត ៖ ជុំ!លឿនណាស់ ។

ធី ៖ ឃើ!កម្លាំងបុកវាច្រើនណាស់ ដែលធ្វើនោះដកកម្លាំងពីស្រុកសិរីសោភ័ណ តាលីម នេះកម្លាំងស្រុកបៀតបៀន ទៅតែ៤ខែទេ ទាំងយប់ទាំងថ្ងៃ និយាយសម្រុកតាវ៉ាល់ មិនធម្មតាទេ ។

ប្រុញ ៖ ខែ៦ ឆ្នាំ៧៧ពូ?

ធី ៖ បាទ!វារាយគ្នាម៉ាកងធំ ម៉ាកងតូចៗរាយៗទៅ ។

ប្រុញ ៖ ពូៗនិយាយថានៅត្រពាំងថ្មហ្នឹង២ឆ្នាំ?

ធី ៖ ២ឆ្នាំ គ្រាន់តែដកចុះដកឡើងដូចថាលើកទំនប់បេះ គេឲ្យកងកុមារម៉ាវរៈហ្នឹង ៣កងធំហើយយុវជនម៉ាវរៈដែរ ២វរៈ បន្ទាប់មកគេដកមកស្ពានស្រែងនេះ គេទុក២វរៈហ្នឹងឯងការពារទំនប់ ។ ទៅលីឈើ កាប់ឈើប៉ុនៗនេះយកមកទុកសង់ធ្វើរបងប៉ុនៗនេះ បន្ដោល ៣ម៉ែត្រ២ម៉ែត្រ កាប់កូនខ្លែងមកលីមកសង់ធ្វើរបង ។ សង់ធ្វើរបងហើយ បានយក

សំរះដាក់ៗរាំងៗកុំឲ្យទឹកវារលកមក កំពក(កំប្លោក) គេជីកដីរី ដីរីតាយ៉យ២នោះជីកកំពក ដាក់ៗដាំតាមជើងទំនប់ហ្នឹង ដាំត្រកួនដាក់ដំបូករាយទៅ តែកើតលឿនតែ១ខែឡើង ពេញៗ ដាក់រាយៗតែបន្តិចៗទេ រំលងតែ១ខែកំពកវាកើតកូនកើតចៅដុះឡើងៗ

ប៊ុនថន : កំប្លោកពូ?

ធី : កំប្លោកហ្នឹងឯងៗ ហើយបើថា មានត្រង់ណាប្រេះស្រាំចង់បាក់បេះ យកកម្ទាំងទៅបុក ហើយ កុំឲ្យវា យុវជនផងកុមារផង៣ថ្ងៃឲ្យរួចៗ សម្រេចថា៣ថ្ងៃឲ្យរួចគឺរួចហើយ ដាក់ឡើងជិតភ្លឺ មិនឲ្យដេកទេវែក កាប់ក្នុងទឹកទៀតៗ កាប់ក្នុងទឹកដល់បែកខ្លាយទឹកបិទ ពន្លត់បេះបើកកាប់ ភក់ក្នុងទឹកហ្នឹងឯង គ្មានថាអ្វី!ទឹកកាប់មិនកើតអីអត់មានប្រកែកទេ ដល់ភ្អែកបិទកាប់ទាំងទឹកហ្នឹង កាប់សុទ្ធតែបិទភ្អែកហ្នឹង កាប់ពីបង្ហាយពេញអស់ហើយខោអាវ គ្មានខ្លាចប្រលាក់មិនប្រលាក់អីទេ ដាក់ទៅហើយ វែកសម្រុកចាក់ គេចុះយើងឡើង យើងឡើងគេចុះ ៣ថ្ងៃថារួចៗ ២ថ្ងៃឲ្យរួចៗ ទប់បិទពីលើហើយបិទកន្លែងជើងៗវាខ្លាចបាក់ បិទទៅលើទៀត កន្ទះម៉ែត្រទៅលើ បិទអាជើងក្រោមក៏បិទអាអ្នកវែកស្មៅដាក់ក៏វែកស្មៅដាក់ទៅ ថាដូចស្រមោចអីចឹង ៗ

ប៊ុនថន : ការងារគេធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន មានកំណត់ធ្វើទេ?

ធី : ២៥សម្រុកអត់មាន គ្រាន់តែស៊ីតែបាយរួចចុះភ្លាម សឹងតែដក់បារីមិនទាន់ផង ម៉ោង ១១ឡើងស៊ីបាយៗរួចឲ្យលាងតែចានរួច រត់ចុះទៀតហើយៗ ឲ្យតែម៉ោង៥ស៊ីបាយរួច ហ៎!ពួកយើងម៉ោង៦ហើយ ចុះទៀត ដាក់ទល់តែម៉ោង១២ ម៉ោង១យប់នោះៗ

ប៊ុនថន : បាទ!ពូកុមារនៅហ្នឹងច្រើនទេ បើតាមពូស្មាន?

ធី : កុមារកាលនៅជាមួយគ្នាវា២០០ ដល់យូរៗទៅបែកនៅសល់តែ១០០ជាងៗ ១០០ ជាងដល់នេះបែក តាស្រាប ទៅនៅខាងស្ពានស្រែងកងធំ ពួកខ្ញុំនៅមា៉កងធំ ដល់យូរៗ ទៅនៅតែ២កងហ្នឹងៗ កាលមុនវា៣កងធំ វរៈសេនាតូចដល់យូរៗទៅវារលួសអារត់មក ដុះផង ឈឺស្លាប់ផងៗ

ប៊ុនថន : បាទ!ឈឺស្លាប់ហ្នឹងច្រើនទេពូ?

ធី : ប្រហែលជា២០នាក់ដែរៗ

ប៊ុនថន : ស្លាប់ដោយសារអីដែរ?

ធី : ស្លាប់ជំងឺរាគមួល ជំងឺហើមៗ

ប៊ុនថន : បាទ! ភាគច្រើនមានពីអាយុប៉ុន្មានដល់ប៉ុន្មានទៅ?

ធី ៖ អាយុមានអា៦ឆ្នាំ ៥ឆ្នាំ ៤ឆ្នាំអាហ្នឹងតិចទេ តែ៤-៥នាក់ទេ ។ បើភាគច្រើនៗអាយុ១៧ឆ្នាំឡើងទៅដល់១៥ឆ្នាំ ។

ប៊ុនថន ៖ ហើយ១ថ្ងៃគេកំណត់ឲ្យធ្វើប៉ុន្មាន ៧ម៉ែត្រគីប?

ធី ៖ គេវាស់តាមរូបភាពយើង ដូចថាតូចៗបេះ អាណាតូចប៉ុនៗកូនខ្ញុំបេះ១ម៉ែត្រគីប តូចៗទោះធ្វើរួចគេមិនថា ធ្វើអត់រួចក៏គេមិនថាដែរ បើថាធំវ័យអាយុ១៤-១៥-១៦-១៧ហើយបន្ទុំហើយ បន្ទុំឲ្យធ្វើឲ្យរួច បើមិនចឹងអត់ឲ្យឡើង ទល់យប់ម៉ោង៧-៨ប៉ុនឲ្យឡើងឲ្យឡើងក្រោយគេ ។ បើអាតូចៗតែមិនឲ្យឡើងវាយំ យំរយ៉ាយំស្រែក ។ ប្រធានកងតម្បាញ តាវ៉ាល់ គាត់ថាកុំអាលបន្ទុំវា វានៅតូចៗត្រពាំងថ្មវាមិនទាន់ដឹងអីទេ ប៉ុនៗនោះ ។

ប្រុញ ៖ អ៊ូ!តាវ៉ាល់ ធ្លាប់និយាយអីចឹងដែរ?

ធី ៖ បាទ! ឲ្យវាឡើងទៅ បើអាធំៗអា១៥-១៦-១៧ លត់វាឲ្យតឹងដៃបន្តិច ដាក់ឲ្យឯងអាពួកធំៗនៅរង្ហុក១០-២០នាក់-៣០នាក់ ។ តូចៗ១០-២០អីចឹងទៅឲ្យឡើងទៅមុន ជួនណាបើវាមិនធ្វើក៏វាអង្គុយយំៗវាឃ្លានបាយវា វាងងឹតខ្ទុះមាន់ ដឹកដៃធ្លាក់លូធ្លាក់អីតែពាស ស្រែកចេកចាច បើអាធៀន នោះវាថ្ងង់ជងធ្លាក់ទៅក្នុងអន្ទុងឮសូរបឿក វាស្រែកអ៊ូ!បែក ថ្ងើមខ្ញុំហើយផ្កាច់ផ្កាន់នៅក្នុងអន្ទុងហ្នឹង ចុះអន្ទុងឡើងស្មើកករ២ម៉ែត្រ ។ ដើរតាមផ្លូវដឹកគ្នាដូចថា១៥-២០នាក់ទៅខ្វាក់មាន់ អ៊ូ!អញរទេះភ្លើង អញក្បាលរទេះភ្លើងហែងនៅឲ្យស្ងៀម វាស្រែក!ប៉ននៗប្រុងប្រៀបត្រៀមចាប់ដៃឲ្យជាប់ អាដាច់អញមិនដឹងទេ ទុកហែងចោលហ្នឹងហើយ ទុកឲ្យហែងដេកអត់បាយចុះ ដឹកទៅដើរៗទៅក៏ធ្លាក់ស្រែកអ៊ួយៗ!ដាច់ខ្សែៗហើយ ហ៊ី!ហែងបានទុកហែងអត់បាយនេះ ហែងមិនឡើងមក គ្នាឡើងអត់រួចដល់ចាប់ដៃអូសឡើងមក ដាក់ចប់ទៅឲ្យវាតោងចបមានគ្នា២នាក់ទាញវាឡើងចេញពីអន្ទុង ហើយក៏ហែងខ្វាក់ហែងមកនៅមុខ ហែងនៅក្រោយមិនកើតទេ ហែងមកមុខ ។

ប៊ុនថន ៖ ពូដូចថាកុមារអីចឹង ដូចថាធ្វើអត់ហើយអីចឹងមានកាត់របបអីទេ?

ធី ៖ អត់ទេ!គ្រាន់តែថាវាឲ្យយើងឡើងក្រោយគេ ខុសគ្នា១ម៉ោងអីឬកន្លះម៉ោង ជួនណាគេអាតូចៗគេស៊ីបាយឡើងឆ្អែត ចូលដេកហើយ បានយើងទៅក្រោយគេ ស៊ីបាយក្រោយគេ ។

ប៊ុនថន ៖ បើសិនជាធ្វើអត់ហើយ ដូចថាដាក់ថែមហើយនៅធ្វើអត់ហើយទៀត?

ធី ៖ អត់ថែមទេ ស្អែកឡើងឲ្យវាស់ អាដែលសល់ហ្នឹងទុកចោលហ្នឹង វាស់២ម៉ែត្រតទៅទៀត

អាសល់ហ្នឹងកាត់ចោល អត់មានយកអាសល់ហ្នឹងបូកអាក្រោយទៀតទេ ។

ប៊ុនថន : ចុះពូថាមានធ្វើឃើត មានផាក់ពីក្រោយមានអីពូ កាលហ្នឹងធ្វើនៅត្រពាំងថ្មប្អូក៏ម៉េច?

ធី : បាទ!ត្រពាំងថ្ម អាហ្នឹងយើងធ្វើបាប យើងធ្វើទារុណកម្មវា ដូចថាយើងធ្វើការយឺត ធ្វើការខ្ជិលមិនលឿនក៏ ធំតែរូបដូចធំត្រឡាច ធ្វើការអី ៗចាញ់កូនក្មេង ។ អាខូចហ្នឹងដាក់បន្តិចប៉ុនៗនេះ កាប់បុកឡើងណែនឲ្យរែកៗឡើងតេសតាសៗ រុញគ្នាប្រានគ្នា អាអ្នករុញហ្នឹងព្រឹងៗមែនទែនដាន់លេខដាក់លេខ១ រួងៗខែឡើង អាគ្នាអ្នករែកចង់ងាប់យំដងអីដងទៅធ្វើបាបណាស់ ឃើញអាឃ្លួយហ្នឹងឯងធ្វើបាបចង់ងាប់ចង់រស់ គ្នាបេះបំរើ ខំស៊ីរែកដងយំដង ។

ប្រុញ : ចុះពូនិយាយថា ដល់យើងឈឺដល់៥ថ្ងៃធ្វើការអត់កើតគេយកមនុស្សហ្នឹងទៅណាពូ?

ធី : ដូចថាយើងធ្វើការគេមើលយើង យើងឈឺ ដល់ពេលគេទៅធ្វើការអស់យើងទៅកន្លែងចុងភៅទៅសុំបាយក្តាំង យើងក្រោកដើរសុំបាយក្តាំង សុំសម្លអីគេ គេឃើញយើងអីចឹងគេកសាងយើងអត់តាមទៀត យើងនៅតែធ្វើចុះទៀត ដូចថាយើងឈឺយើងដេកនៅកន្លែងទៅ ។ បាយគេយកមកឲ្យ អ្នកឈឺគេឲ្យផ្សេង បាយគេឲ្យស៊ីមុនអ្នកជាទៀតមុនអ្នកធ្វើការទៀត ដូចថាស៊ីបាយសម្លម្នាក់ម៉ាកូនចានស៊ីទៅ ដើរទៅសុំបាយក្តាំងសុំត្រីសុំអីគេថាស៊ីសម្លមិនកើតសុំត្រីគេ យើងឈឺស៊ីរកតែឆ្ងាញ់ ចង់ស៊ីឆ្ងាញ់ជាងគេអ្នកធ្វើការ គេបញ្ចេញពលកម្មគេហត់នឿយគេស៊ីសម្លដែរ យើងចង់តែអាំងអី អានេះដូចថាវារើសៗរកឆ្ងាញ់ កសាងថាហើយមិនស្តាប់ទៀត ។

ប៊ុនថន : ពូធ្វើទំនប់ហ្នឹងបើតាមពូស្មាន កម្លាំងហ្នឹងប៉ុន្មាននាក់?

ធី : ចូលរាប់ពាន់ហើយម៉ាតំបន់៥មានតិចអី ។

ប៊ុនថន : បាទ!ប្រហែលជាប៉ុន្មានពូ បើស្មាន?

ធី : កាលបើធ្វើកងវ៉ាខ្ញុំដឹងចំនួន១៥០០នាក់ ។ ត្រពាំងថ្មនេះមិនដឹងទេ ដបូងត្រពាំងថ្មហ្នឹងបូកសរុបរាប់ម៉ឺន ។

ប៊ុនថន : រាប់ម៉ឺននាក់ពូ?

ធី : បាទ!ចុះចល័តសិរីសោភ័ណ ចល័តថ្មពួក ចល័តស្រុកព្រះនេត្រព្រះ ភ្នំស្រុក ៤ស្រុកនោះបុកតែម៉ាកន្លែងបានជារាប់ម៉ឺន ។

ប៊ុនថន : អីចឹងមានទាំងកងចល័តសិរីសោភ័ណ?

ធី ៖ សិរីសោភ័ណ ចល័តថ្មពួក ស្រុកព្រះនេត្រ ស្រុកភ្នំស្រុក ចល័តតំបន់ផ្សេង ចល័តតំបន់គឺតាវ៉ាល់ គ្រប់គ្រងផ្សេង ចែកតាមខ័ណ្ឌៗគ្នា ។

ប៊ុនថន ៖ អីចឹងចល័តតំបន់ហ្នឹងគ្រប់គ្រងខុសពីចល័តស្រុក?

ធី ៖ បាទ! គេដើរម៉ោតំបន់៥ ដើរទៅមកខាងភ្នំស្រុកទៅ មកខាងព្រះនេត្រព្រះទៅ ខាងសិរីសោភ័ណឲ្យតែកន្លែងត្រង់ណាគេធ្វើអាងទឹកធំ ត្រូវយកកម្លាំងទៅបុក ចល័តតំបន់ហ្នឹងបុកហើយ បុកទាំងយប់ទាំងថ្ងៃ ធ្វើទាល់តែរួច ។

ប៊ុនថន ៖ ពូមានដឹងថាចល័តខាងសិរីសោភ័ណខាងណាអ្នកគ្រប់គ្រងទេពូ?

ធី ៖ តាលាប់ ។

ប៊ុនថន ៖ ចុះខាងថ្មពួក?

ធី ៖ ថ្មពួកអត់ស្គាល់ទេ ថ្មពួកនៅឆ្ងាយ បើតាលាប់ នៅជាប់នេះចល័តតំបន់ ។

ប៊ុនថន ៖ ចុះខាងព្រះនេត្រព្រះយើងពីណាវិញ?

ធី ៖ ព្រះនេត្រព្រះតាមោង ។

ប៊ុនថន ៖ តាមោងហ្នឹងគាត់ក្តាប់ ។ ហើយខាងភ្នំស្រុកពីណាវិញ?

ធី ៖ អត់ស្គាល់ ។

ប្រុញ ៖ នៅភូមិភាគពាយ័ព្យហ្នឹងពីណាគេគណៈភូមិភាគពូ?

ធី ៖ គេថាតាញឹម ប្រធានភូមិភាគ តាជាលហ្នឹងអនុប្រធាន ។

ប្រុញ ៖ តាញឹម ហ្នឹងគាត់ដែលចុះមកពូ?

ធី ៖ អត់ដែលមកទេ មកតែតាជាល ។

ប្រុញ ៖ តាជាលធ្លាប់ចុះមក?

ធី ៖ តាញឹម មកតែត្រឹមតំបន់ទេ ។

ប្រុញ ៖ គាត់ធ្លាប់ចុះមកដល់ត្រពាំងថ្មនេះដែរពូ?

ធី ៖ មកតែតាជាល ចុះមកមើល ។

ប្រុញ ៖ ពូធ្លាប់ឃើញគាត់ដែរ?

ធី ៖ ឃើញ មកជាមួយតាហ៊ីងតាអីហ្នឹង ។

ប្រុញ ៖ មកជាមួយតាហ៊ីង?

ធី ៖ បាទ! ដល់ពេលគេចាប់យកទៅវ៉ៃចោល វ៉ៃម៉ោខ្សែគេហ្នឹងបន្តបន្ទាប់គ្នាហ្នឹងរដើនៗ ។ ចុះវាថា កម្មាភិបាលពាយ័ព្យក្បត់ និរតីមកចាប់បណ្តើរៗ ។

ប៊ុនថន ៖ ចាប់ហ្នឹងពូដឹងទេ?

ធី ៖ ស្រាប់តែបាត់ក៏ពូប្រធានគេប្រជុំប្រាប់ ពួកកម្មាភិបាលយើងទៅអស់ហើយ គេយកទៅរៀនសូត្រហើយ ចុះទៅចុះមកគេយកទៅរៀនសូត្រអត់ដែលមកវិញទេ ។

ប៊ុនថន ៖ ចាប់គាត់ហើយពីណាអ្នកឡើងជំនួសវិញពូ?

ធី ៖ តាពាល់ ។

ប៊ុនថន ៖ តាពាល់ហ្នឹងគាត់ឡើងជំនួសពីណា?

ធី ៖ ជំនួសតាវ៉ាល់ហ្នឹង ប្រធានចល័តតំបន់ តាពាល់ តាស៊ុម តាយន់ ។ តាយន់ប្រធាន តាពាល់អនុ តាស៊ុមសមាជិកពរូបហ្នឹង ខាងនិរតី ។

ប៊ុនថន ៖ ខាងនិរតី គាត់ផ្លាស់មកក្រោយទេ?

ធី ៖ ផ្លាស់មកឆ្នាំ៧៧ ខែ៧ ខែធ្លាក់ភ្លៀងខែគេធ្វើស្រែ ។

ប្រុញ ៖ កាលហ្នឹងឈប់ធ្វើត្រពាំងថ្មហើយពូ?

ធី ៖ ចុះខ្ញុំនៅស្ទូងហ្នឹង ។

ប្រុញ ៖ ឈប់ជីកដីជីកអីហើយ?

ធី ៖ ឈប់លើកហើយប៉ុនធ្វើស្រែ ឲ្យនៅធ្វើស្រែ ធ្វើស្រែឲ្យបិទប្រពន្ធ័ភ្លឺតូចៗហ្នឹង ភ្ជួរពួកយុវជនភ្ជួរគោ ស្រីៗស្ទូងនារីៗស្ទូង ខ្ញុំកុមារប្រព័ន្ធភ្លឺៗរែកសំណាបឲ្យគេ រែកសំណាបបេះឲ្យគេ ហើយនារីៗគេអ្នកស្ទូង ។

ប្រុញ ៖ អីចឹងអ្នកដែលចុះមកកញ្ចឹកញាប់ធ្វើនៅត្រពាំងថ្ម មានតែតាវ៉ាល់ តាហ៊ីង ហើយតាជាលគាត់ចុះមកមួងម្កាលជាមួយតាហ៊ីង?

ធី ៖ បាទ!មួងម្កាលមើលទិដ្ឋភាព មើងអ្នកប្រូត ។

ប្រុញ ៖ ហើយតាហ៊ីង តាជាល ពេលគាត់ចុះមកម៉េចដែរពូ?

ធី ៖ ខ្ញុំមិនដែលដឹងទេ ។

ប្រុញ ៖ គាត់ជួបតែជាមួយតាវ៉ាល់ទេ?

ធី ៖ បាទ!គ្រាន់តែជួបថា អ៊ើ!មិត្តយើង ស្នាដៃល្អបានជោគជ័យហើយ ធ្វើប៉ុននេះបានសម្រេចជោគជ័យតាមគោលការណ៍របស់អង្គការ យើងមានវីរៈភាពខ្ពង់ខ្ពស់ណាស់ ។

ប្រុញ ៖ ហ្នឹងតាហ៊ីងនិយាយ?

ធី ៖ បាទ! ថ្ងៃថ្នាណាស់ដែលមិត្តយើងលះបង់ ជីវិតបុព្វហេតុជាតិមាតុភូមិ តស៊ូបួរផ្តាច់ គាត់មកលើកទឹកចិត្តសរសើរយើង ។

ប៊ុនថន :　ពូធ្វើហ្នឹងមានដែលឃើញពួកបរទេស ពួកអីមកទេពូ ពួកចិនពួកអី?

ធី :　បើកាលនៅស្វាយឃើញ កាលខ្ញុំធ្វើចំការកប្បាសនៅស្វាយហ្នឹង ។

ប៊ុនថន :　នៅព្រះនេត្រព្រះពូ?

ធី :　បាទ!ឆ្នាំ៧៨ ខែ៨-៩ហ្នឹងហើយឃើញចិនមកទូតហ្នឹង និយាយពីផាត់ឡើង មកដល់មើញតែឡានទូតមក ហ៎!មកហើយឲ្យលឿន ដាក់ប៉ុបប៉ាប់ៗៗអ៊ូ!កាប់ឡើងញាប់ស្មោះចុះគេថតនោះ ឃើញនៅស្វាយអាជិតស្រុក ។

ប៊ុនថន :　ចំការកប្បាសហ្នឹង កាលហ្នឹងនៅណាពូ?

ធី :　កងវ៉ា បើកឡានទៅមើលទៅថតទៅអីឡើង វាថាដីខ្មែរជីវជាតិល្អណាស់ ដាំអីក៏កើត កាលហ្នឹងវាជំនួយថ្នាំជំនួយធុងបាញ់ឲ្យ ក្នុងមួយដបវាយកតែ៧ដៃទេ ។

ប៊ុនថន :　ចិនហ្នឹង?

ធី :　ហ្នឹងហើយ វាជួយថ្នាំ ជួយធុងបាញ់ជួយឧបករណ៍ ។

ប៊ុនថន :　ម៉េចក៏ពូដឹងថាគេយក៧ដៃ?

ធី :　ប្រធានកងគេប្រាប់ ប្រធានកងគេប្រជុំប្រាប់ ថាជំនួយឲ្យតែខ្វះឧបករណ៍វាយការណ៍ឲ្យគេ គេផ្តល់ឲ្យ ។ ចិនហ្នឹងនិយាយពីផាត់ៗហើយខ្ពស់ សុទ្ធតែគ្នាប៉ុល ពតហ្នឹង កឡើងរួញក្បាលឆកៗទៀត ។

ប៊ុនថន :　ហើយនៅត្រពាំងថ្មដែលមកទេ?

ធី :　អត់ទេ!អត់ដែលមកទេ ហើយប្រធានកងគេប្រាប់ថា នេះទូតចិនមកដាក់ទូតនៅតំបន់៥ យើង៣នាក់ ប្រធានកងគេប្រាប់ខ្ញុំ ។ ទូតចិនយើងធ្វើការខ្លាំងណាស់ គេមកថតយើងដាក់ទស្សនាវដ្ដី(ស្តាប់មិនបាន) ។

ប្រុញ :　ចិនហ្នឹងឈ្មោះអីខ្លះទៅពូ?

ធី :　អត់ស្គាល់គេទេ គេមិនដែលមកជិតយើង គេគ្រាន់តែមកថតតែម៉ាភ្លាតឲ្យយើងកាប់ឲ្យលឿនឲ្យយើងធ្វើការឲ្យខ្លាំង ហើយគេបើកឡានទៅវិញបាត់ ។ គេគ្រាន់តែមកឈរមើលកប្បាស មកថតឈរមើលកប្បាស ថតអ្នកធ្វើការ ថតហើយទៅទៀត ទៅដើរនោះទៅថតដើរហើយបានគេទៅលិចៗរួចបានគេទៅជីឡូ ហើយចុះទៅវិញ កន្លែងទូតគេនៅកន្លែងស្វាយ ។

ប៊ុនថន :　ពូនៅនេះមានស្លាប់ច្រើនទេពូ ធ្វើនៅត្រពាំងថ្ម?

ធី ៈ គ្រពាំងថ្មមិនសូវស្លាប់ទេ ស្លាប់តិចជាងនៅកងវ៉ា នៅកងវ៉ាស្លាប់ច្រើនណាស់ៗ វាចាញ់ខ្ញុំចាញ់ឡើងញាក់ គ្រាន់តែញាក់ឡើងម៉ាខែ ថាតែងាប់ ទាល់តែគេបញ្ជូនមកនេះៗ បានបាត់ ញាក់ឡើងចូលក្នុងបាវកប្បាសហើយ ញាក់ទាំងបាវកប្បាសទៀត ញាក់វាក្តៅមែនទែនក្តៅរទេះរទែងវារឡើងសរសរឡើងអី ដល់ក្តៅមែនទែន ...ស្បោងសង្កត់ពីលើ មើលមែកឈើសុទ្ធតែបន្លា ដីងខ្លួនម៉ាភាំងៗ ក្តៅខ្លាំង ជួយខ្ញុំផងមើលគេយកដុំថ្មសង្កត់ខ្ញុំ អាខ្លះមើលវារឡើងតាមសរសរ ពេលឯងគ្រដាក់ដីងខ្លួន មានអាផ្សេងគ្រុនឡើង អាខ្លះក៏រត់ទៅឡើងដើមអំពិលដើមអីក្តៅខ្លាំង ។ ហើយពេទ្យគេមិនដឹងទៅណា ទៅចុះតាមកងបាត់ ឲ្យៗតែថ្នាំអាចម៍ទន្សាយហ្នឹង លាបទៅមិនឃើញបាត់ អីចឹងឡើងខៀវ ឡើងលឿង ។

ប្រុញ ៈ កាលនៅគ្រពាំងថ្មតាវ៉ាល់ ហៅប្រជុំញឹកញាប់ទេពូ?

ធី ៈ ប្រជុំម៉ាអាទិត្យប្រជុំម្តង ។

ប្រុញ ៈ ប្រជុំជាមួយតាវ៉ាល់ ហ្នង?

ធី ៈ ហ្នឹងហើយប្រជុំជាមួយតាវ៉ាល់ ។

ប្រុញ ៈ អ្ហូ! ពេលដែលខាងតាហ៊ីង មកហើយប្រជុំជាមួយតាវ៉ាល់ តាវ៉ាល់ហៅខាងចល័តតំបន់ទៅប្រជុំតទៀតទៅ?

ធី ៈ បាទ! ប្រជុំតទៀតទៅ ប្រជុំពេលយប់ ម៉ោង៧/ម៉ោង៨ ទៅដាក់មេក្រូទៀតនោះ ។

ប្រុញ ៈ កាចទេតាវ៉ាល់ ពូ?

ធី ៈ អ្ហូ! កាចណាស់ ។

ប្រុញ ៈ គាត់ដែលនិយាយគំរាមសម្លាប់គំរាមអីទេ ពេលយើងអត់ធ្វើការធ្វើអី?

ធី ៈ វ៉ៃចល័តបើគាត់ពាក់អាវខ្មៅ រុំក្បាលកន្សែងពាក់មួកស្លឹកត្នោតយ៉ៃៗ ដល់យុវជនវាឡើងទៅធ្វើការ កងជិតខ្ញុំវានិយាយគ្នា ឈប់ដក់បារី អាមួយនោះវាថា អ្ហូ! អញដល់អាអញខំលើកទាំងយប់ទាំងថ្ងៃអញមិនដេកមិនបានពួនអញចង់ងាប់សូរ(អស់កម្លាំង)ដល់ថាអីចឹងនោះទាញដងវែកបានដាក់ហ្នងម៉ោក ។

ប្រុញ ៈ គ្រាន់តែគាត់និយាយអីចឹងតាវ៉ាល់ វ៉ៃហ្នង?

ធី ៈ វ៉ៃ ។

ប្រុញ ៈ គ្រាន់តែនិយាយថា ធ្វើការហត់អីចឹង ។

ធី ៈ វ៉ៃហើយ ប្រាប់ប្រធានកងឲ្យយកទៅវ៉ៃចោលហ្នង ។

ប្រុញ ៈ អ្ហូ! វ៉ៃគាត់ចោលហ្នង?

ធី : បាទ! ។

ប៉ុនថន : ម៉េចបានពូដឹង?

ធី : ចុះបើនៅជិតគ្នាហ្នឹង កងរាយ ដូចថារាយម៉ាជួរ នៅជិតប្រធានកងដឹងទៅនិយាយប្រាប់ប្រជុំហើយមេក្រុមៗប្រាប់ ធ្វើការមើលកូនចៅឲ្យល្អណ៎ា និយាយហើយឈរនិយាយគ្នាមិនចង់ធ្វើការ ប្រណែនដឹង អាប្រធានកងគ្មានធ្វើដើរតែថា អញ......ស្រេចៗ និយាយនោះនើយយ៉ាងណា អត់ឲ្យលាន់មាត់អួយៗ ស៊ីទ្រាំងាប់ចោល ងាប់នឹងការងារ តស៊ូប៉ុននោះទម្រាំបានរស់ៗ

ប្រុញ : ចុះពេលយើងធ្វើការចឹង តាវ៉ាល់ មានបានរាយការណ៍ប្រាប់តាហ៊ឹងស្រុតាអី?

ធី : អត់ដឹង អារឿងការងារសំងាត់របស់គេ យើងអត់ដឹងៗ យើងដឹងតែការងារក្នុងសមរភូមិយើងៗ

ប្រុញ : ដឹងធ្វើការខាងក្រោមៗ

ធី : វាទាញដងរែកវ៉ៃស្រែក «ឯងអាសក្តិភូមិអានាយទុន ឯងនេះមិនមែនកម្មករកសិករទេអ្នកណាមេកង» ស្រែកហៅមេកងៗ

ប្រុញ : ថាឲ្យចឹងម៉ង ថាពួកសក្តិភូមិ?

ធី : អឺ! ពួកសក្តិភូមិ ឯងធ្លាប់តែជិះឡាន អង្គុយលើផ្ទះថ្ម ឯងមិនមែនកម្មករ កសិករ បដិវត្តសុទ្ធតែវណ្ណៈកម្មករ កសិករ អត់មានវណ្ណៈនាយទុនៗ

ប្រុញ : តាវ៉ាល់និយាយចឹង?

ធី : នោះហើយវណ្ណៈកម្មករកសិករៗ

ប៉ុនថន : ពូដូចការងារអីកំណត់ធ្វើៗ ហើយធ្វើពូរាយការណ៍ទៅលើ ឬក៏មានអ្នកដែលរបាយការណ៍អីចឹង?

ធី : អត់ទេ មិនដែលមានៗ

ប៉ុនថន : អត់ដែលមានទេ?

ធី : តែខុសកសាងណែនាំតាមក្រុមតាមកងមិនបានប្រាប់រាយការណ៍ទៅប្រធានវរៈទៅយកទៅបាត់ទៅៗ

ប្រុញ : និយាយចំតាវ៉ាល់ដាក់ការងារឲ្យហើយត្រូវតែធ្វើឲ្យហើយ?

ធី : អឺ! ធ្វើឲ្យហើយ ទោះបីមិនរួចត្រង់ណាធ្វើទាំងយប់ទៀត ភ្លៀងធ្វើទាំងភ្លៀងៗ

ប៉ុនថន : ចឹងកងពូដឹងតែហើយ ដាក់ផែនការដឹងតែហើយ?

ធី : ដឹងតែហើយ ស៊ូននាលអត់ផ្ទុយវែកដឹងក់ក៏មាន វែកដីដើរដល់គ្នាបុកដើមឈើ ចុយ! ឯងមិនទៅឲ្យលឿន លឿនណាអាមួយចាល់មុខនោះ វែកដឹងក់ក៏មាន។ ជួនកាលដោះខ្សែ ត្រៀមទាំងយប់ចេះដើរៗផក់ដុលគ្នាប៉ុកចេះ អានោះលីចបលីបង្គីរដើរក្រោយផក់ដើរបុក ចបវ៉ាប៉ុកចិញ្ចើម។

ប៊ុនថន : ចឹងពូបើធ្វើយឺតអី ពូមានដែនការម៉េច និយាយថាដឹកនាំឲ្យធ្វើលឿន?

ធី : ប៉ុនយើងមានតាមប្រធាន ដូចថាយើងមិនស្រួលគេដឹងថា ខ្ញុំអត់ស្រួលខ្ញុំឈឺរាគអាចម៍ ឈឺពោះ ខ្ញុំអត់ហ៊ានសម្រាកទេ។ អានោះគេដឹងគេឃើញយើងរត់ដុះ មើលអាចម៍យើង ទៀត ខ្លាចយើងដុះសតិអារម្មណ៍ ព្រោះឃើញអាចម៍យើងរាគមែន យើងរត់ដុះម៉ាព្រឹក ៣-៤ដង សង្ស័យយើងដើរទៅមើលទៀត។ ឃើញយើងទៅអង្គុយដុះគេដើរទៅ បើ យើងក្រោកចេញ គេដើរទៅមើលអាចម៍។

ប្រុញ : អត់ជឿយើង?

ធី : នោះហើយ ដល់រាគមែន គេអត់សូវហ៊ានធ្វើបាប បង្ខំទេ អើយ!រាគអាចម៍អត់ស្រួល ទេបង ឲ្យធ្វើតិចៗធ្វើម៉េចបានតែមកហើយ។

ប៊ុនថន : ចឹងពូចេញពីត្រពាំងថ្មទៅណាទៀត?

ធី : កងវ៉ារើស២ដង ៧៦នៅមង្គ ៧៨នៅមង្គ ត្រពាំងថ្មនៅ២ដងដែរ។

ប៊ុនថន : ពូនៅត្រពាំងថ្មដល់បែកដែរ?

ធី : ទេ! ដែលបែកនឹងនៅកងវ៉ា។

ប៊ុនថន : បែកហើយពូទៅណាទៀត?

ធី : រត់មកផ្ទះ។

ប៊ុនថន : ពូការឆ្នាំប៉ុន្មាន?

ធី : ខ្ញុំការ៨៦។

ប៊ុនថន : ហើយបច្ចុប្បន្ន កូនប៉ុន្មាននាក់?

ធី : កូន៥នាក់។

ប៊ុនថន : ហើយពូធ្វើអីដែរសព្វថ្ងៃនេះ?

ធី : គ្មានធ្វើស្អី ប្រជាជនធម្មតា ឈឺនឹងដើរមិនរួច។

ប៊ុនថន : ឈឺអីវិញ?

ធី : ឈឺលោកសន្ទាក់ ឈឺដើរឆ្ងាយផ្សា។

ប្រុញ ៖ ឈឺតាំងពីមុនមក ហើយម៉េចអ៊ំ?

ធី ៖ ទើបឈឺឆ្នាំទៅមិញ ។

ប្រុញ ៖ ដោយសារយើងវាលទ្ធផលធ្វើការនោះហត់ពេក?

ធី ៖ បាទ! ហត់ពេករលាកសន្ទាក់ ...សរសៃមិនបានដេកទៀតស្រែកអួយៗ ខ្ញុំសព្វថ្ងៃនៅចុះ ហើយ ប្រពន្ធខ្ញុំរោគរបេងរោគប្រចាំកាយ ។

ប្រុញ ៖ ពូកូនប៉ុន្មានហើយ?

ធី ៖ កូន៥ ។

ប្រុញ ៖ បានរៀននៅណាដែរ នៅរៀននៅនេះដែរ?

ធី ៖ រៀនមួយនោះ ប្រឡងជាប់គ្រូហើយ ដល់រៀនស្វាយនោះ ជាប់គ្រូហើយ ដល់ពេលគ្រូ មិនមានប្រាក់ខែប្រាក់អី សញ្ញាប័ត្រនៅកំប៉េះចោលប្រឡងបាក់ឌុប ។

ប្រុញ ៖ គាត់ជាប់បាក់ឌុបហើយ?

ធី ៖ ទើបនឹងជាប់ដែរ ជាប់ទុតិយភូមិ ទៅថៃតែថ្ងៃ២៥មកវិញ ការនៅរៀន ។

ប្រុញ ៖ ពូធ្លាប់បួសលោក?

ធី ៖ បួស... ។

ប៊ុនថន ៖ ចឹងពូខ្ញុំអរគុណច្រើន ។

«ចប់»